# កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center*

*ខ្ញុំបានព្យាយាមវិលត្រឡប់ទៅរកស្មារតី ខ្ញុំបានព្យាយាមដើម្បីបំពេញនូវស្មារតី។*
*ប៉ុន្តែ ខ្ញុំមានតែកម្លាំងកាយ រីឯស្មារតី គឺនៅឆ្ងាយ ហើយព្រលឹងរបស់ខ្ញុំ គឺមិនស្ថិតនៅក្នុងខ្លួននោះទេ ។*

-អ្នកស្រី **ចាន់ សុជាតិ** ដើមបណ្ដឹងរដ្ឋប្បវេណី[1]

## ផ្នែកទី ១៖ ទិដ្ឋភាពទូទៅ

នៅសប្តាហ៍នេះ អង្គជំនុំជម្រះ បានស្ដាប់សេចក្ដីថ្លែងការណ៍ពីការទទួលរងទុក្ខវេទនាពីដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១២រូប។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំង ១២រូបនេះ ត្រូវបានជ្រើសរើសយកក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣,៨៦៦នាក់ ដែលបានទទួលស្គាល់នៅក្នុងសំណុំរឿង០០២ ដោយផ្អែកទៅលើ “ភស្តុតាងដែលពួកគេ អាចផ្ដល់ពីការរងទុក្ខវេទនា ទំនាក់ទំនងរវាងភស្តុតាង និងបទឧក្រិដ្ឋកម្ម ដែលកំពុងត្រូវបានកាត់ទោសក្នុងសំណុំរឿង ០០២/០១ និងភាពខុសៗគ្នានៃការប៉ះពាល់ (ការរងទុក្ខវេទនា) ដែលបានកើតឡើង។[2] សក្ខីកម្ម មានភាពរំជើបរំជួល ហើយនៅពេលខ្លះបានធ្វើឱ្យដើមបណ្ដឹងរដ្ឋប្បវេណី និងសមាជិកតុលាការដទៃទៀតស្រក់ទឹកភ្នែក។

ដោយយោងតាមនីតិវិធី ដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្ដីសម្រេចចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតឲ្យសួរសំណួរទៅកាន់សហជនជាប់ចោទ។[3] លោក **ខៀវ សំផន** បានឆ្លើយតបនឹងសំណួរទាំងអស់ដែលបានសួរដោយដើមបណ្ដឹងរដ្ឋប្បវេណី។ បើទោះបីជាលោក **នួន ជា** អាចឆ្លើយតបទៅនឹងសំណួរពីបន្ទប់ឃុំឃាំងតាមរយៈឧបករណ៍សំឡេង និងវីដេអូក៏ដោយ តែលោកបានបដិសេធមិនឆ្លើយសំណួរមួយចំនួនដែរ ដោយសារតែគាត់មិនមានសម្បទា (សុខភាព) គ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងសំណួរ។ ទោះជាយ៉ាងណាក៏ដោយ ខណៈដែលឆ្លើយតបទៅនឹងសំណួរដែលបានចោទសួរលោក **នួន ជា** គាត់បានធ្វើឲ្យតុលាការភ្ញាក់ផ្អើល ដោយទទួលយកការទទួលខុសត្រូវផ្នែក "សីលធម៌" ចំពោះបទល្មើសដែលប្រព្រឹត្តឡើងនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

## ផ្នែកទី ២ ៖ សក្ខីកម្មសង្ខេបរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីថ្លែងការណ៍នៃរងទុក្ខសោកវេទនា

ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មពីបទពិសោធន៍របស់ពួកគេអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ជីវិតរស់នៅក្នុងសហករណ៍ ការរើសអើងប្រឆាំងនឹង "ប្រជាជនថ្មី" និងការបោសសម្អាតពួកមន្ត្រី **លន់ នល់**។ លោកស្រី **អេលីហ្សាប៊ែត ស៊ីម៉ូណូ ហ្វត (Mrs. Elisabeth Simonneau Fort)** សហមេធាវីនាំមុខអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី បានរម្លឹកដល់អង្គជំនុំជម្រះថា មានសាក្សីជាច្រើនទទួលរងនូវអារម្មណ៍រំជើបរំជួលយ៉ាងខ្លាំង នៅពេលដែលរម្លឹកឡើងវិញអំពីការរងទុក្ខ ដែលពួកបានគេជួបប្រទះនៅក្នុងអំឡុងពេលនៃរបប និងក្រោយពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយយោងតាមសេចក្តីសម្រេចមុនរបស់អង្គជំនុំជម្រះសាលាដំបូង សាក្សីត្រូវបានអនុញ្ញាតឱ្យសួរសំណួរទៅកាន់សហជនជាប់ចោទផងដែរ។[4] លោក **ខៀវ សំផន** បានឆ្លើយតបទៅនឹងសំណួរទាំងអស់ ដែលបានចោទសួរមកលើគាត់។ ការឆ្លើយតបរបស់គាត់ភាគច្រើននោះ បានឆ្លុះបញ្ចាំងអំពីសេចក្តីថ្លែងការណ៍ពីលើកមុន ដែលបានលើកឡើងថា តំណែងរបស់លោកជាប្រមុខរដ្ឋ មិនបានផ្តល់ឱ្យគាត់នូវអំណាចនីតិប្រតិបត្តិណាមួយទេ។ **លោក នួន ជា** បានបដិសេធមិនឆ្លើយតបទៅនឹងសំណួរមួយចំនួនដោយសារតែគាត់អស់កម្លាំងពេក។ ប៉ុន្តែ គាត់បានបានឆ្លើយតបថា គាត់បានបដិសេធពីអត្ថិភាពនៃគោលនយោបាយសម្លាប់មនុស្ស ដោយលើកឡើងពីតម្រូវការមនុស្សក្នុងការការពារប្រទេស ហើយគាត់ក៏បានលើកឡើងទៀតថា គោលនយោបាយ គឺដើម្បីលុបបំបាត់ "សមាសភាពអាក្រក់" នេះសំដៅតែទៅលើលក្ខណៈដែលគេមិនចង់បានក្នុងបុគ្គលជាជាងមនុស្សជារួម។

### ក. សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុទ្ធាវី (TCCP-151)

ដើមបណ្តឹងរដ្ឋប្បវេណីគឺ អ្នកស្រី **ស៊ូ សុទ្ធាវី** អាយុ ៧៣ឆ្នាំ បានផ្តល់ចម្លើយនៅថ្ងៃចន្ទ នៅសប្តាហ៍នេះ។[5] អ្នកស្រី បានរម្លឹកឡើងវិញអំពីអំពើហិង្សាផ្លូវភេទ ដែលអ្នកស្រីបានទទួលរងដោយសារជាមនុស្សខ្ជើយ និងការបាត់បង់ដៃគូអ្នកស្រី និងមិត្តរួមការងារក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

### *ក.១. ការជម្លៀសប្រជាជនចេញពីភ្នំពេញ និងការជម្លៀសក្រោយៗទៀត*

នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ អ្នកស្រី **ស៊ូ សុទ្ធាវី** ស្ថិតនៅក្នុងផ្ទះរបស់គាត់នៅក្បែរស្តាតអូឡាំពិកនៅទីក្រុងភ្នំពេញ ហើយទាហានខ្មែរក្រហមប្រដាប់ដោយអាវុធ បានចូលទៅផ្ទះរបស់គាត់។ គាត់បានរម្លឹកដល់ការចម្អិនអាហារក្នុងផ្ទះបាយ ហើយបានឮស្នូរបាញ់កាំភ្លើងនៅខាងក្នុងផ្ទះ។ គាត់មិនបានមើលឃើញថាតើពួកទាហានបានបាញ់សម្លាប់មនុស្សបួននាក់ដែលជាមិត្តភ័ក្ររបស់គាត់នៅខាងក្នុងផ្ទះឬយ៉ាងនោះទេ ប៉ុន្តែបានសន្និដ្ឋានថា ពួកគេត្រូវបានសម្លាប់ ដោយសារគាត់មិនដែលបានឃើញពួកគេម្តងទៀតទេ។ សាក្សី បានរម្លឹកថា ទាហានខ្មែរក្រហម បានដើរជាក្បួនអមប្រជាជនតាមដងផ្លូវ ហើយអ្នកស្រីក៏បានលើកឡើងថា អ្នកស្រី ត្រូវបានបង្គាប់ឱ្យធ្វើដំណើរតាមបណ្តោយផ្លូវជាតិលេខ ១ បើទោះបីជា បំណងប្រាថ្នារបស់គាត់ចង់ធ្វើដំណើរទៅកាន់ភូមិកំណើតនៅក្នុងខេត្តតាកែវតាមផ្លូវជាតិលេខ២ ក៏ដោយ។ នៅពេលដែលឆ្លងកាត់ស្ពានព្រះមុន្នីវង្ស អ្នកស្រី បានឃើញមនុស្សត្រូវបាញ់ស្លាប់ ហើយបានអះអាងថា កម្មាភិបាលខ្មែរក្រហមទាំងនោះ មិនបានផ្តល់ជំនួយអ្វីសោះដល់ជនភៀសខ្លួន។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ សាក្សី បានចាំថា មានការជួបប្រជុំមនុស្សខ្មៅយផ្សេងទៀតនៅឯវត្តចម្ប៉ា រួមទាំងមិត្តភ័ក្រ្តគាត់ម្នាក់ បានប្រាប់គាត់ថា មានសុទ្ធតែឈាមបន្ទាប់ពីត្រូវបានគេរំលោភតាមរន្ធគូថ។ អ្នកស្រី **ស៊ូ សុទ្ធារី** ក៏បានផ្តល់សក្ខីកម្មថា គាត់ក៏ត្រូវបានគេរំលោភដែរ ប៉ុន្តែ អ្នកស្រី មិនច្បាស់លាស់អំពីពេលវេលាដែលរឿងនេះបានកើតឡើងនោះទេ។ បន្ទាប់មកសាក្សី ត្រូវបានគេជម្លៀសទៅកាន់ស្រុកល្វាឯម ក្រោយមកធ្វើដំណើរទៅស្វាយជ្រុំ បន្ទាប់មក ហែលទឹកឆ្លងកាត់ទន្លេ ទៅកាន់ក្រុងតាខ្មៅ និងព្រែកហូ។ បន្ទាប់ពីហ្នឹងមក គាត់ត្រូវបានគេជម្លៀសចេញជាលើកចុងក្រោយទៅកាន់ខេត្តតាកែវ។

### *ក.២. បទពិសោធន៍ធ្វើការនៅក្នុងសហករណ៍ខេត្តតាកែវ*

ដើមបណ្តឹងរដ្ឋប្បវេណី បានរម្លឹកឡើងពីការវាយបំបែកថ្ម និងការធ្វើពលកម្មធ្ងន់ធ្ងរផ្សេងទៀតនៅក្នុងសហករណ៍ជាមួយនឹង "ប្រជាជន១៧មេសា" នៅក្នុងខេត្តតាកែវ។ គាត់បានប្រាប់តុលាការថាៈ “ប្រជាជន ១៧មេសា” ត្រូវបានបំបែកចេញពី "ប្រជាជនចាស់" ហើយត្រូវបានគេចាត់ទុកជាអ្នកទោសសង្គ្រាម”។ នៅពេលចោទសួរដោយសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក **វាំងសង់ វ៉ាយដ៍ ដេស្តាឯល (Mr. Vincent de Wild de Estamel)** អំពីការរើសអើងដែលគាត់បានជួបប្រទះ ដោយសារតែបញ្ហាលើអត្តសញ្ញាណយេនឌ័ររបស់គាត់។ សាក្សី បានឆ្លើយតបថា មនុស្សខ្មើយតែងតែត្រូវបានគេរើសអើងនៅក្នុងសង្គម ប៉ុន្តែ គាត់បានបន្ថែមទៀតថា ដើម្បីបន្តរស់រានមានជីវិត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកស្រីត្រូវតែ "រស់នៅដូចជាបុរសម្នាក់"។

### *ក.៣. ទុក្ខសោកវេទនា និងព្យសនកម្ម ដោយសារតែបទឧក្រិដ្ឋក្នុងករណី ០០២*

ដោយមានការជជីកសួរដេញដោលពីអ្នកស្រី **ស៊ីន សុវ៉ន** ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី **ស៊ូ សុទ្ធារី** បានពណ៌នាពីព្យសនកម្មលើរូបរាងកាយ ដែលគាត់បានទទួលរងដោយសារការធ្វើទារុណកម្ម និងការចាប់រំលោភដែលគាត់បានជួបប្រទះអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ ដោយរួមមានបញ្ហាៈ បាក់ចង្កា បញ្ហាភ្នែកមើលមិនឃើញ និងចលនាជើងរបស់គាត់ចុះថយ។ គាត់ក៏បាននិយាយអំពីរបួសផ្លូវចិត្ត ដែលគាត់បានជួបប្រទះដោយសារបទឧក្រិដ្ឋ និងការបាត់បង់ឪពុកម្តាយ បងប្អូនសាច់ញាតិ និងដៃគូរបស់គាត់។ អ្នកស្រី **ស៊ូ សុទ្ធារី** បានពន្យល់ថា ការស្នើសុំសំណងរបស់គាត់ គឺជាសំណងរួមមួយនៅក្នុងទម្រង់បណ្ណាល័យអំពីប្រវត្តិសាស្រ្តខ្មែរក្រហម និងចេតិយ ដើម្បីរម្លឹកដល់វិញ្ញាណក្ខន្ធដល់ជនរងគ្រោះពីរបបខ្មែរក្រហមនេះ។

### *ក.៤. សំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី សួរទៅកាន់សហជនជាប់ចោទ*

អ្នកស្រី បានសួរសំណួរដល់សហជនជាប់ចោទ ថាតើពួកគេបានដឹងអំពីអំពើឃោរឃៅ ដែលគាត់បានរៀបរាប់ ឬថាតើពួកគេបានដឹងអ្វីបន្ថែមចំពោះពន្ធនាគារនៅគុកទួលស្លែង និងជើងឯកដែរទេ? លោក **ខៀវ សំផន** បានឆ្លើយតបថា លោកមិនមែនជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា (ដូចជា **ប៉ុល ពត** ជាដើម) នោះទេ និងគ្រាន់តែបានចូលរួមបក្សកុម្មុយនីស្តកម្ពុជា ដើម្បីការពារប្រទេសកម្ពុជា ពីការដណ្តើមយកពីប្រទេសវៀតណាម។ លោក **នួន ជា** បានបដិសេធមិនឆ្លើយតបទៅនឹងសំណួរ។

### *ក.៥. ឥរិយាបថរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន*

ដើមបណ្ដឹងរដ្ឋប្បវេណី បានប្ដេជ្ញាផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ បើទោះបីជាឃើញថា មិនសប្បាយចិត្ត និងបានយំស្ទើរតែទាំងស្រុងនៃការផ្ដល់សក្ខីកម្ម។ គាត់បានប្រាប់តុលាការថា គាត់បានរង់ចាំយុត្តិធម៌អស់រយៈពេល ៣០ឆ្នាំ មកហើយ និងបានសង្ឃឹមទុកថា សក្ខីកម្មរបស់គាត់ នឹងអាចជូនជាដំណឹងដល់សាធារណជនអំពីទុក្ខវេទនា និងជួយដល់ក្មេងជំនាន់ក្រោយ ដើម្បីធានាថាមិនឱ្យមានប្រវត្តិសាស្រ្តច្រំដែលកើតឡើងជាថ្មីម្ដងទៀត។

## ខ. សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី **អូន ផល្លី** (TCPP-2)

លោក **អូន ផល្លី**[6] មានអាយុ ១០ឆ្នាំ ក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ លោកបានផ្ដល់សក្ខីកម្មអំពីការជម្លៀស ការបាត់ខ្លួនក្រុមគ្រួសាររបស់គាត់ និងលក្ខខណ្ឌការងារជាច្រើនដែលគាត់បានជួបប្រទះនៅក្នុងសហករណ៍ផ្សេងៗគ្នា។ គាត់ និងក្រុមគ្រួសាររបស់គាត់ ត្រូវបានជម្លៀសចេញពីផ្ទះរបស់ពួកគេនៅទីក្រុងភ្នំពេញ ម្ដុំតោពីរ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយសាក្សីបានបន្ថែមទៀតថា គាត់បានក្លាយជាក្មេងកំព្រាក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

### *ខ.១. ការជម្លៀសប្រជាជនចេញពីភ្នំពេញ*

នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សី បានចាំថា បានឃើញមនុស្សលើកទង់ជាតិស្វាគមន៍ទាហានខ្មែរក្រហម ដែលកំពុងតែចូលមកទីក្រុងភ្នំពេញ។ ទោះជាយ៉ាងណាក៏ដោយ ភ្លាមៗបន្ទាប់ពីទាហាន បានចាប់ផ្ដើមបាញ់ឡើងលើមេឃ បង្ខំឱ្យប្រជាជនចាកចេញពីទីក្រុង គាត់បានលើកឡើងថា ទាហានខ្មែរក្រហមបានជូនដំណឹងឱ្យពួកគេថា ការជម្លៀស គឺជាការចាំបាច់ណាស់ដើម្បី "រៀបចំ" ទីក្រុង ហើយពួកគេនឹងអនុញ្ញាតឱ្យវិលត្រឡប់មកវិញបន្ទាប់រយៈពេលពីរទៅបីថ្ងៃ។ គាត់បានចងចាំថា សមាជិកគ្រួសារប្រាំពីរនាក់ ត្រូវភ្ជង់នឹងកាំភ្លើង ហើយបានប្រាប់ឱ្យចាកចេញពីផ្ទះរបស់គាត់ភ្លាមនៅម្ដុំ **តោពីរ**។

គ្រួសាររបស់លោក **អូន ផល្លី** តម្រូវឱ្យដើររយៈពេល ១៥ថ្ងៃ ទៅកាន់ឃុំព្រែកផ្ទូរ ខេត្តព្រៃវែង ដោយយួរបានតែឥវ៉ាន់ផ្ទាល់ខ្លួន និងពប្អូនៗរបស់ពួកគេ។ ប៉ុន្មានថ្ងៃក្រោយមក ពួកទាហានខ្មែរក្រហម បានកោះហៅឪពុករបស់សាក្សី ដោយចោទប្រកាន់ឲ្យគាត់ទៅចូលរួមវគ្គសិក្សាមួយ។ សាក្សីបានអះអាងថា គាត់នៅពេលនោះនៅវ័យក្មេងពេក មិនដឹងថាតើឪពុករបស់គាត់ធ្វើការឱ្យរបប **លន់ នល់** ឬយ៉ាងណាទេ។ ឪពុករបស់គាត់មិនដែលវិលត្រឡប់មកវិញទេ ហើយក្រៅពីក្ដីបារម្ភ សាក្សីត្រូវបានគេបញ្ជូនឱ្យទៅរស់នៅជាមួយជីដូនរបស់គាត់នៅព្រែកញ្ចៅតំបន់ក្បែរៗគ្នា។ បន្ទាប់មក ជីដូនរបស់លោក **អូន ផល្លី** បានឱ្យដំណឹងគាត់ថា ម្ដាយ និងបងប្អូនរបស់គាត់ ត្រូវបានគេនាំយកទៅឆ្ងាយ និងសម្លាប់ចោលហើយ។

ក្រៅពីសោកនាដកម្មការបាត់បង់ក្រុមគ្រួសាររបស់គាត់ លោក **អូន ផល្លី** បានរៀបរាប់ជីវិតនៅក្នុងខេត្តព្រៃវែងថា "មិនសូវជាមានការលំបាកពេកទេ"។ គាត់បានបញ្ជាក់ពីការមានអាហារគ្រប់គ្រាន់ដែលអាចរកបាន និងបានលើកឡើងថា ទោះបីជា កុមារត្រូវបានគេឱ្យទៅរកមើលគំនរស្លឹកឈើ សម្រាប់យកមកធ្វើជី និងឱ្យហ្វូងគោក៏ដោយ ក៏ពួកគេត្រូវបានអនុញ្ញាតឱ្យទៅរស់នៅជាមួយឪពុកម្ដាយរបស់ពួកគេ។

### ខ.២. ការជម្លៀសបន្តបន្ទាប់ៗ និងបទពិសោធន៍ការងារនៅក្នុងសហករណ៍ខេត្តបាត់ដំបង

សាក្សី នឹកមិនឃើញនៅថ្ងៃណាឲ្យច្បាស់លាស់នោះទេ ប៉ុន្តែ ដូចជានៅក្នុងឆ្នាំ១៩៧៦ ឬ ១៩៧៧ គាត់ និងគ្រួសាររបស់យាយគាត់ ត្រូវបានជម្លៀសចេញពីព្រៃថ្នោ ហើយនាំទៅកាន់ទីក្រុងភ្នំពេញតាមរយៈអ្នកលឿងដោយកប៉ាល់ទឹក បន្ទាប់មកក៏បានធ្វើដំណើរតាមរថភ្លើងទៅកាន់ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ អ្នកមកដល់ថ្មី ក៏បានចាត់ចែងឱ្យរស់នៅ និងធ្វើការងារនៅក្នុងសហករណ៍ផ្សេងៗគ្នា។ នៅខេត្តបាត់ដំបង សាក្សីបានផ្តល់សក្ខីកម្មថា គាត់បានក្លាយជាក្មេងកំព្រា បន្ទាប់ពីលោកយាយ និងបងប្អូនជីដូនមួយរបស់គាត់ បានស្លាប់ដោយសារការអត់ឃ្លាន។ លោក **អួន ផល្លី** ត្រូវបានចាត់តាំងឱ្យទៅកាន់អង្គភាពកុមារនៅភ្នំត្រជាក់ចិត្ត ហើយបានចាំថាត្រូវបានបង្ខំឱ្យធ្វើការធ្ងន់ធ្ងរ ដោយទទួលបានរបបអាហារតិចតួច។ គាត់ក៏បានរៀបរាប់ថាកុមារជារឿយៗត្រូវបានវាយដំ ឬបង្គាប់ឱ្យទៅវាយគ្នាទៅវិញទៅមក។ លោកបានរត់គេចចេញពីអង្គភាពដោយជោគជ័យ បន្ទាប់ពីការប៉ុនប៉ងរត់គេចបរាជ័យម្តងមក ដើម្បីទៅកាន់ភូមិរបស់គាត់វិញ។ នៅក្នុងអំឡុងពេលសាកសួរដោយសហព្រះរាជអាជ្ញាជាតិ លោក **ច័ន្ទ តារាស្មី** សាក្សីក៏បានរៀបរាប់ផងដែរថា ប្រជាជនកំពុងធ្វើការក្រោមការឃ្លាំមើលមិនដាច់នៅក្នុងអង្គភាពចល័ត ហើយគ្រប់គ្នាភ័យខ្លាចការសម្លាប់។

### ខ.៣. ទុក្ខវេទនា និងព្យសនកម្មដោយសារតែបទឧក្រិដ្ឋក្នុងករណី០០២

លោក **អួន ផល្លី** បានសង្កត់ធ្ងន់អំពីការឈឺចាប់ផ្នែកស្មារតីចំពោះការរស់នៅដោយគ្មានការគាំទ្រពីគ្រួសាររបស់គាត់ ដោយសារតែគាត់បានបាត់បង់សមាជិកគ្រួសារ នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ គាត់ក៏បានសម្តែងនូវការឈឺចាប់ដោយបានឃើញពីការស្លាប់លោកយាយ និងបងប្អូនជីដូនមួយរបស់គាត់ដោយសារការអត់ឃ្លាន។ ដោយអះអាងថាខ្លួនមានអារម្មណ៍ថាជា "មនុស្សឃ្លាតឆ្ងាយពីគ្រួសារ" សាក្សីបានពន្យល់ថា ព្រឹត្តិការណ៍ទាំងនោះ បានធ្វើឱ្យគាត់ទៅចូលរួមជាមួយកងទ័ពដែលគាំទ្រដោយវៀតណាម បន្ទាប់ពីខ្មែរក្រហមដួលរលំ។ អំឡុងពេលដែលបំពេញការងារ គាត់បានឈឺជម្ងឺគ្រុនចាញ់ ហើយឥឡូវនេះរស់នៅក្នុងស្ថានភាពជាមនុស្សពិការ។

### ខ.៤. ឥរិយាបថរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន

សាក្សី ពិតជាមានអារម្មណ៍ជ្រួលច្របល់នៅពេលផ្តល់សក្ខីកម្ម ជាពិសេស គឺនៅពេលរៀបរាប់អំពីបទពិសោធន៍រស់នៅជាក្មេងកំព្រា។ ពីព្រោះតែសាក្សី គឺជាក្មេងតែម្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មិនអាចរៀបរាប់ទៅលើសេចក្តីលម្អិត ដែលបានសួរទៅកាន់គាត់ទេ រួមទាំងហេតុអ្វីបានជាការជម្លៀសប្រជាជនកើតឡើង និងការងាររបស់ឪពុកគាត់មុនពេលដែលភ្នំពេញដួលរលំ។ ទោះជាយ៉ាងណាក៏ដោយ គាត់បានបើកចំហអំពីការកម្រិតទៅលើអ្វីដែលគាត់ អាចចងចាំនៅក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ និងចែករំលែកបញ្ហានេះដោយបើកចំហជាមួយនឹងតុលាការ។

## គ. សក្ខីកម្មរបស់អ្នកស្រី សាំង រ៉ាត់ (TCPP-129)

អ្នកស្រី **សាំង រ៉ាត់**[7] អាយុ ៧២ ឆ្នាំ ជាស្ត្រីដែលបានបាត់បង់គ្រួសារទាំងមូលរបស់គាត់នៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ បានឡើងឆ្លើយបំភ្លឺនៅថ្ងៃចន្ទ។ អ្នកស្រី **សាំង រ៉ាត់** បានផ្តល់សក្ខីកម្មអំពីការរង

ទុក្ខវេទនា ដែលអ្នកស្រីបានទទួលរងនៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ រួមទាំង ខ្លួនអ្នកស្រីផ្ទាល់ និងការជម្លៀសគ្រួសាររបស់អ្នកស្រីចេញពីខេត្តកំពង់ស្ពឺ ទៅកាន់ខេត្តបាត់ដំបងនៅចុងឆ្នាំ ១៩៧៥។

### *គ.១. ការជម្លៀសប្រជាជនចេញពីខេត្តកំពង់ស្ពឺ*

អ្នកស្រី **សាំង រ៉ាត់** កើតនៅក្នុងស្រុកសំរោង ខេត្តកំពង់ស្ពឺ។ នៅចុងឆ្នាំ ១៩៧៥ អ្នកស្រីបានចាំថា អ្នកស្រីត្រូវបានជម្លៀសទៅកាន់ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ អ្នកស្រី បានជម្រាបដល់អង្គជំនុំជម្រះថា មុនដំបូង ប្រជាជនរស់នៅក្នុងភូមិរបស់គាត់ ត្រូវបានប្រាប់ឱ្យទៅធ្វើការនៅឯវាលស្រែ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីធ្វើការអស់រយៈពេល ៧ (ប្រាំពីរ) ខែមក ប្រជាជនមកពីភូមិរបស់អ្នកស្រី និងអ្នកដែលនៅជុំវិញភូមិ ត្រូវបានបង្ខំឱ្យជម្លៀសចេញ។ អ្នកស្រីបានជឿថា ការជម្លៀសប្រជាជនចេញ គឺពិតជាមានសារសំខាន់ ពីព្រោះ កាលណាមិនសុខចិត្ត គេអាចចោទប្រកាន់ថាជាសត្រូវ។ អ្នកស្រី បានចាំពីការបង្គាប់ឱ្យឡើងជិះរថយន្តមួយក្នុងចំណោមឡានប្រមាណជាដប់គ្រឿង ជាមួយនឹងប្តី និងកូនប្រុសបួននាក់របស់អ្នកស្រី។ គ្រួសារចំនួនប្រាំផ្សេងទៀតដែលមកពីភូមិរបស់អ្នកស្រីដែរនោះ ក៏ត្រូវបានបង្គាប់ឱ្យឡើងជិះរថយន្តជាមួយនឹងប្រជាជនដែលមកពីភូមិផ្សេងៗគ្នាដែរ ដែលអ្នកស្រីបានឃើញពួកគេឡើងឡាន។ រថយន្តបានបើកតាមបណ្តោយផ្លូវជាតិលេខ៣ ហើយបានមកដល់ខេត្តពោធិ៍សាត់នៅពេលព្រឹកព្រលឹម។ អ្នកភូមិ បានស្នាក់នៅក្នុងខេត្តពោធិ៍សាត់ពីរថ្ងៃ ហើយពួកគេបានទទួលអាហារញ៉ាំនៅទីនោះ។ ពីរថ្ងៃក្រោយមក ពួកគេបានជិះរថភ្លើងចេញពីខេត្តកំពង់ស្ពឺទៅកាន់ខេត្តបាត់ដំបង។ សាក្សីបានចាំទៀតថា អាហារមិនបានផ្តល់ឱ្យទេក្នុងការធ្វើដំណើរនេះ ហើយកម្មាភិបាលខ្មែរក្រហម បានតាមដានមើលអ្នកភៀសខ្លួនយ៉ាងខ្ជាប់ខ្ជួន។ នៅពេលដែលអ្នកភៀសខ្លួនបានមកដល់ស្រុកមោងឫស្សី មេស្រុកបានស្វាគមន៍ និងបានចាត់ចែងឱ្យពួកគេរស់នៅក្នុងភូមិដែលបានរៀបចំរួចរាល់។

### *គ.២. បទពិសោធន៍ការងារនៅក្នុងសហករណ៍ខេត្តបាត់ដំបង*

នៅឯស្រុកមោងឫស្សី សមាជិកគ្រួសាររបស់អ្នកស្រី **សាំង រ៉ាត់** ត្រូវបានគេបំបែកចេញទៅកាន់អង្គភាពផ្សេងៗគ្នា។ ប្តីរបស់អ្នកស្រី ត្រូវបានគេបញ្ជូនទៅធ្វើការនៅវាលស្រែ។ កូនៗអ្នកស្រី ត្រូវបានបញ្ជូនទៅអង្គភាពកុមារ ហើយអ្នកស្រីផ្ទាល់ ត្រូវបានចាត់តាំងឱ្យទៅធ្វើការលើកទំនប់ទឹក។ អាហារមិនមានគ្រប់គ្រាន់ទេ ដែលជាមូលហេតុធ្វើឱ្យកូនរបស់អ្នកស្រីស្លាប់នៅចុងឆ្នាំ១៩៧៦ ដោយសារការអត់អាហារ។ ប្តីរបស់អ្នកស្រីក៏បានស្លាប់ដែរដោយសារតែការអត់ឃ្លាន និងអស់កម្លាំងខ្លាំងពេក។ អ្នកស្រី **សាំង រ៉ាត់** ត្រូវបានប្រាប់មិនឱ្យយំ នៅពេលសមាជិកគ្រួសាររបស់អ្នកស្រីស្លាប់ បើមិនដូច្នេះទេ "ខ្ញុំអាចនឹងត្រូវបានយកទៅសម្លាប់ ឬចោទថាជាជនក្បត់"។

នៅចំពេលមួយ អំឡុងពេលស្នាក់នៅរបស់អ្នកស្រីនៅខេត្តបាត់ដំបង សាក្សី បានចងចាំពីការឈឺខ្លាំងធ្ងន់ធ្ងរ ហើយត្រូវបានបញ្ជូនទៅមន្ទីរពេទ្យនៅវត្តចាស់។ ខណៈដែលនៅក្នុងមន្ទីរពេទ្យ អ្នកស្រីបានកត់សម្គាល់ឃើញថា អ្នកជំងឺទាំងអស់ត្រូវបានគេផ្តល់ថ្នាំប្រភេទដូចៗគ្នា ហើយបានស្លាប់បន្ទាប់ពីលេបថ្នាំហ្នឹង។ ដើមបណ្តឹងរដ្ឋប្បវេណី បានសម្រេចចិត្តមិនលេបថ្នាំ ហើយបានចាកចេញពីមន្ទីរពេទ្យបន្ទាប់ពីរយៈពេលពីរសប្តាហ៍។ បន្ទាប់ពីវិលត្រឡប់មកវិញ សាក្សីក៏ទៅធ្វើការលើកទំនប់ ហើយត្រូវបានបង្ខំឱ្យធ្វើការលំបាកដូចមុន បើទោះបីជាកំពុងតែងើបពីឈឺក៏ដោយ។ អ្នកស្រី បាននៅទីនោះរហូតដល់ពេលខ្មែរក្រហមដួលរលំ។

### *គ.៣. ការប្រព្រឹត្តចំពោះ "ប្រជាជនថ្មី" និង "ប្រជាជនមូលដ្ឋាន"*

សាក្សី បានផ្តល់សក្ខីកម្មថា "ប្រជាជនថ្មី" និង "ប្រជាជនមូលដ្ឋាន" ទទួលបានការប្រព្រឹត្តមកលើពួកគេមិនស្មើភាពគ្នានោះទេ ចំពោះការផ្គត់ផ្គង់អាហារ ល័ក្ខខ័ណ្ឌនៃការរស់នៅ និងការចាត់ចែងឱ្យធ្វើការងារ។ អ្នកស្រី បានរម្លឹកឡើងថា ភាគច្រើននៃចំនួនអ្នកដែលអត់អាហាររហូតដល់ស្លាប់ ឬបាត់ខ្លួន គឺជា "ប្រជាជន ១៧មេសា"។ ទោះជាយ៉ាងណាក៏ដោយ អ្នកស្រីបានយល់ច្រលំពីការចាត់ថ្នាក់ជាក្រុម ពីព្រោះគ្រួសាររបស់អ្នកស្រីត្រូវបានចាត់ទុកដូចជា "ប្រជាជនថ្មី" បើទោះបីជាត្រូវបានជម្លៀសពីតំបន់ជនបទមួយទៅកាន់តំបន់មួយទៀតក៏ដោយ។

### *គ.៤. ទុក្ខវេទនា និងព្យសនកម្ម ដោយសារតែបទឧក្រិដ្ឋក្នុងករណី ០០២*

សាក្សី បានរម្លឹកទៅដល់ "ការឈឺចាប់ដែលមិនអាចទ្រាំបាន" ដែលអ្នកស្រីទទួលរងពេលត្រឡប់ទៅកាន់ភូមិកំណើតរបស់អ្នកស្រី ដោយគ្មានសមាជិកគ្រួសារ និងសាច់ញាតិបងប្អូន បន្ទាប់ពីការដួលរលំរបបខ្មែរក្រហម។ អ្នកស្រី បានប្រៀបធៀបខ្លួនឯងទៅនឹងតួអង្គរឿងព្រេងរបស់ខ្មែរគឺនាង **បាជាចា** ដើម្បីរៀបរាប់អំពីការឈឺចាប់នៃការរស់ដោយគ្មានការគាំទ្រពីកូនៗទាំងបួននាក់ និងប្តីរបស់អ្នកស្រី។ ទីបំផុត អ្នកស្រីបានស្នើសុំអង្គជំនុំជម្រះឱ្យស្វែងរកយុត្តិធម៌សម្រាប់ក្រុមគ្រួសាររបស់អ្នកស្រី។

### *គ.៥. ឥរិយាបថរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន*

ដើមបណ្តឹងរដ្ឋប្បវេណី ជាស្ត្រីទន់ខ្សោយម្នាក់ ដែលពោរពេញទៅដោយទុក្ខព្រួយ នៅពេលរម្លឹកឡើងវិញអំពីការរងទុក្ខវេទនា ដែលអ្នកស្រីបានស៊ូទ្រាំអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រី ពោរពេញទៅដោយអារម្មណ៍រំជើបរំជួលយ៉ាងខ្លាំង នៅក្នុងឱកាសជាច្រើនដងនៅពេលផ្តល់សក្ខីកម្ម ជាពិសេសនោះគឺនៅពេលរម្លឹកឡើងវិញអំពីការស្លាប់របស់ក្រុមគ្រួសាររបស់អ្នកស្រី។ ទោះជាយ៉ាងណាក៏ដោយ អ្នកស្រីបានប្តេជ្ញាចូលរួមក្នុងដំណើរការនីតិវិធី ហើយឆ្លើយតបទៅនឹងសំណួរទាំងអស់ ដែលចោទសួរទៅកាន់អ្នកស្រីឱ្យបានល្អជាទីបំផុតតាមដែលអាចធ្វើបាន។

## ឃ. សក្ខីកម្មរបស់លោក យស ផល (TCCP-172)

សាក្សី **យស ផល** ជាដើមបណ្តឹងរដ្ឋប្បវេណីទីបួន ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការនៅថ្ងៃចន្ទ។[8] សាក្សីមានអាយុ ៥៨ ឆ្នាំរូបនេះ ជាអតីតទាហាន **លន់ នល់** ហើយសព្វថ្ងៃរស់នៅក្នុងស្រុកត្រាំងខេត្តតាកែវ។ លោក **យស ផល** បានផ្តល់សក្ខីកម្មទៅលើរូបភាពបញ្ចាំងពីអតីតមន្ត្រី **លន់ នល់** និងពីរបៀបដែលគាត់បានរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារការលាក់កំបាំងតំណែងរបស់លោកជាមន្ត្រីប៉ូលីសមួយនៅក្នុងរបប **លន់ នល់**។ បើទោះបីជាភាពជឿជាក់នៃរឿងរ៉ាវរបស់លោក ត្រូវបានជំទាស់ដោយមេធាវីការពារក្តីលោក **នួន ជា** យ៉ាងណាមិញ សាក្សីបានបន្តថា គាត់បានឃើញពួកខ្មែរក្រហមបង្ហាញមន្ត្រីយោធា **លន់ នល់** និងបានដកចេញអ្នកទាំងឡាយណា ដែលមានឋានៈអនុសេនីយ៍ទោ និងឋានៈខ្ពស់ជាងនេះ។

### *ឃ.១.  ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

លោក **យស ផល** បានរម្លឹកឡើងថា នៅថ្ងៃ ១៧ មេសា ១៩៧៥ នៅប្រមាណជា ម៉ោង ៨ ព្រឹក គាត់បានចាកចេញពីបន្ទាយទាហានមហោស្រពចតុមុខ ដើរតាមផ្លូវរបស់មេបញ្ជាការរបស់គាត់ដែលបានគេចខ្លួនតាមម៉ូតូ។ បន្ទាប់មក សាក្សីបានជួបពួកទាហានខ្មែរក្រហម ដែលបានប្រាប់ឱ្យគាត់ដោះស្បែកជើង និងមួកទាហានរបស់គាត់ដែលជាសញ្ញានៃការចុះចាញ់។ បន្ទាប់មក គាត់បានដើរដោយជើងទទេនៅក្នុងឯកសណ្ឋានប៉ូលីសរបស់គាត់ទៅកាន់ពេទ្យចិន បន្ទាប់ពីទាហានខ្មែរក្រហមស្ថិតក្នុងសំលៀកបំពាក់ស៊ីវិល បានឆែកអាវុធរបស់គាត់។ បន្ទាប់ពីបានចាកចេញពីពេទ្យចិន លោកបានធ្វើដំណើរទៅភាគខាងជើង រួចហើយឈប់នៅផ្សារធំថ្មី ជាកន្លែងដែលគាត់បានឃើញមន្ត្រីយោធាជាន់ខ្ពស់ **លន់ នល់** មួយរូបគឺលោក ឧត្តមសេនីយ៍ត្រី **ឈិន ឈួន** ឆ្លងកាត់ក្បួនដង្ហែររថយន្តរបស់គាត់ឆ្ពោះទៅរកទិសដៅក្រសួងព័ត៌មាន។ សាក្សីបានបន្តទៅកាន់ស្ពានជ្រោយចង្វារ ដែលគាត់ត្រូវបានសួរម្តងទៀតថា តើគាត់មានប្រដាប់ដោយអាវុធដែរទេ។ លោក **យស ផល** បានអះអាងថា គាត់បានអនុញ្ញាតឱ្យឆ្លងកាត់ ដោយសារតែគាត់បានបញ្ជាក់យ៉ាងសាមញ្ញថា គាត់ពុំមានកាន់អាវុធ បើទោះបីជាគាត់បានកំពុងស្ថិតក្នុងឯកសណ្ឋានប៉ូលីសក៏ដោយ។ ដោយមានបំណងប្រមូលតវ៉ាន់របស់គាត់ សាក្សីបានធ្វើដំណើរទៅកាន់វត្តចិនដំដែក ដែលខ្មែរក្រហមបានប្រាប់គាត់ឱ្យចាកចេញ ហើយបានគំរាមគាត់ដោយបាញ់ឡើងលើអាកាស។ គាត់នឹកឃើញឡើងវិញថា ខ្មែរក្រហមបានប្រាប់ឱ្យគាត់ឱ្យជិះសាឡាងឆ្លងកាត់ទន្លេទៅកាន់ព្រែកក្ដាមរយៈពេលបីថ្ងៃ ដោយសារពួកគេត្រូវការរៀបចំទីក្រុងឡើងវិញ និងជៀសវាងការទម្លាក់គ្រាប់បែករបស់អាមេរិក។ ចំពោះការធ្វើដំណើរពីជ្រោយចង្វារទៅកាន់ស្ពានព្រែកក្ដាម សាក្សីបានចាំថា បានឃើញសាកសពដែលមានអាយុខុសៗគ្នានៅពាសពេញផ្លូវ ស្ថិតនៅក្នុងសម្លៀកបំពាក់ទាំងយោធា និងស៊ីវិល។

### *ឃ.២.  ការជម្លៀសប្រជាជនចេញជាបន្តបន្ទាប់*

លោក **យស ផល** បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានគេបង្ខំឲ្យចាកចេញជាលើកទីពីរពីស្រុកផ្អាវទៅកាន់ភូមិតាមាន់ នៅជិតព្រំដែនខេត្តតាកែវ និងខេត្តកំពត។ គាត់បានប្រាប់ថា នៅពេលទៅដល់ទីនោះ គាត់បានជួបឪពុកម្តាយរបស់គាត់ដែលបានប្រាប់គាត់ថា គាត់ត្រូវបានគេយកទៅពន្ធនាគារ។ លោក **យស ផល** បានចាំថា គាត់បានឃើញ "ប្រជាជនថ្មី" ជាច្រើនជាមួយនឹងទារក បានដើរចូលទៅក្នុងការិយាល័យពន្ធនាគារតូចមួយ។ សាក្សីជឿជាក់ថា ពួកគេគឺជា "ប្រជាជនថ្មី" ព្រោះពួកគេបានស្លៀកពាក់ខោអាវពណ៌ ហើយមាន "ក្បាលពោះធំៗ" ដែលគាត់បានបញ្ជាក់ថា ពួកគេមកពីគ្រួសារធូរធារ ប្រៀបធៀបទៅនឹងប្រជាជនមូលដ្ឋានដែលស្លៀកពាក់បំពាក់ពណ៌ខ្មៅ។

### *ឃ.៣.  ការពិនិត្យមើលពួកមន្ត្រីប៉ូលីស និងយោធា លន់ នល់*

លោក **យស ផល** បានផ្តល់សក្ខីកម្មថា នៅក្នុងស្រុកផ្អាវ ពួកខ្មែរក្រហមបានប្រកាសថា ទាហាន និងមន្ត្រី **លន់ នល់** អាចនឹងវិលត្រឡប់ទៅកាន់ប៉ុស្តិ៍របស់ពួកគេពីមុនវិញ។ សាក្សី បានលើកឡើងថា អតីតអនុសេនីយ៍ទោរបស់ **លន់ នល់** មួយចំនួន បានផ្តល់ជីវប្រវត្តិពិតទៅឱ្យពួកខ្មែរក្រហម ពីព្រោះពួកគេជឿជាក់ទៅលើសេចក្តីប្រកាសនោះ។ ទោះជាយ៉ាងណាក៏ដោយ សាក្សីបានចាំថា បន្ទាប់ពីប្រមូលជីវប្រវត្តិរួចរាល់ហើយ

ខ្មែរក្រហមបានឲ្យតម្រង់ជួរតាមឋានៈ វរសេនីយត្រី អនុសេនីទោយ៍ អនុសេនីយឯក ឬឋានៈខ្ពស់ជាងនេះ ហើយបាននាំពួកគេ និងក្រុមគ្រួសាររបស់ពួកគេទៅកាន់វត្តជើងព្រៃ ក្នុងភូមិផ្តៅ។ ទាហាន **លន់ នល់** ដែលមានឋានៈទាប ត្រូវបានអនុញ្ញាតឱ្យស្នាក់នៅក្នុងវត្តផ្ការ។ សាក្សីបានជឿថា គាត់នៅមានជីវិត ព្រោះគាត់បានប្រាប់ពួកខ្មែរក្រហមថា គាត់ជាជនស៊ីវិល និងជា "បេក្ខជនភ្នាក់ងារបម្រុងនៅក្នុងរដ្ឋាភិបាល"។ គាត់បានថ្លែងថា គាត់បានជ្រើសយកការលាក់អត្តសញ្ញាណរបស់គាត់ បន្ទាប់ពីគាត់បានឃើញសាកសពទាហាន **លន់ នល់** ក្នុងអំឡុងពេលជម្លៀសគាត់ចេញពីទីក្រុងភ្នំពេញ និងបន្ទាប់ពីគាត់បានជួបជាមួយនឹងស្ត្រីម្នាក់ដែលគាត់បានស្គាល់ថា បានព្រមានមិនឱ្យគាត់ទំលាយព័ត៌មានអំពីអត្តសញ្ញាណពិតរបស់គាត់ទៅឱ្យពួកខ្មែរក្រហម ។

នៅចំណុចមួយផ្សេងទៀតក្នុងសក្ខីកម្មរបស់លោក **យស ផល** គាត់ចាំថា ខណៈដែលគាត់កំពុងធ្វើការនៅក្នុងអង្គភាពចល័តមួយនៅក្នុងស្រុកត្រាំងនោះ ពួកខ្មែរក្រហមតម្រូវឱ្យមានសមាជិក១០០នាក់របស់អង្គភាពសរសេរជីវប្រវត្តិប្រចាំខែ។ នៅពេលមួយ នៅក្នុងឆ្នាំ១៩៧៧ គាត់បានចាំថា មានមនុស្ស ៩៩នាក់មកពីអង្គភាពរបស់គាត់ត្រូវបានសម្លាប់ បន្ទាប់ពីសាវតាររបស់ពួកគេ បានលាតត្រដាងចេញពីជីវប្រវត្តិពួកគេ។ គាត់គឺជាមនុស្សតែម្នាក់គត់ដែលរស់រានមានជីវិត។ គាត់បានអះអាងថា គាត់បានរួចផុតពីការស្លាប់ដោយសារតែបានរក្សាជាប់ដោយមិនផ្លាស់ប្តូរថា គាត់គឺជាសិស្សនៅក្នុងជីវប្រវត្តិរបស់គាត់។ គាត់បាននិយាយថា: "ខ្ញុំមានការអាណិតយ៉ាងខ្លាំងចំពោះមិត្តភក្តិរបស់ខ្ញុំ ដែលមិនបានប្រាប់ពួកគេពីការពិត ប៉ុន្តែ ខ្ញុំមិនហ៊ានប្រាប់ពួកគេឱ្យនិយាយកុហកនោះដែរ"។

### *ឃ.៤. ទុក្ខវេទនា និងព្យសនកម្ម ដោយសារតែបទឧក្រិដ្ឋក្នុងករណី ០០២*

លោក **យស ផល** បានចាំពីការស្លាប់សាច់ញាតិរបស់គាត់ ហើយជាពិសេស ឪពុករបស់គាត់ដែលក្រោយមកធ្លាក់ខ្លួនឈឺ ត្រូវបានគេចាក់ថ្នាំនឹងទឹកធម្មតាដោយពួកខ្មែរក្រហម។ សាក្សី ក៏បានរម្លឹកឡើងពីរឿងដែលគាត់ត្រូវបានរារាំងមិនឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយគូដណ្តឹងរបស់គាត់ ហើយត្រូវបានប្រាប់ថា "ក្នុងនាមជាកូនប្រុសរបស់អង្គការ" វាជាការទទួលខុសត្រូវរបស់អង្គការ ដើម្បីរៀបចំអាពាហ៍ពិពាហ៍មួយដែលសមរម្យសម្រាប់គាត់។ ចំពោះការរៀបចំអាពាហ៍ពិពាហ៍ដែលរៀបចំដោយអង្គការ សាក្សីបានរៀបរាប់ថា "បុរសរូបរាងអាក្រក់ [ត្រូវបាន] រៀបការជាមួយនឹងស្ត្រីស្អាត អ្នកគ្មានបញ្ហា [ត្រូវបាន] រៀបការជាមួយដែលមានបញ្ហា"។

ចំពោះរបួសផ្លូវចិត្តរបស់សាក្សី គាត់បានប្រាប់ទៅកាន់អង្គជំនុំជម្រះ ពីរបៀបដែលគាត់ត្រូវបានគេធ្វើឱ្យ "ឈឺញ៉ាំរតតាក់" និងមានអារម្មណ៍ថា ធ្ងន់នៅក្នុងដើមទ្រូងរបស់គាត់រាល់ពេលដែលគាត់បានរម្លឹកពីព្រឹត្តិការណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានប្តឹងទៅអង្គជំនុំជម្រះដើម្បីរកយុត្តិធម៌ ហើយបានលើកសំណើជាសំណងចំនួនបី រួមមាន៖ ការសាងសង់ស្តូប ដើម្បីរំលឹកដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតក្នុងអំឡុងរបបនេះ បណ្ណាល័យឯកសារខ្មែរក្រហម និងការព្យាបាលដោយឥតគិតថ្លៃមួយ។

## *ឃ.៥. ការសួរសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី សួរទៅកាន់សហជនជាប់ចោទ*

នៅវគ្គបញ្ចប់នៃការសាកសួររបស់មេធាវីរបស់គាត់ លោក **យស ផល** បានចោទជាសំណួរចំនួនប្រាំមួយទៅកាន់សហជនជាប់ចោទ។ សាក្សី បានទាមទារឱ្យដឹងថា មូលហេតុអ្វីបានជាប្រជាជនកម្ពុជា ត្រូវបានគេសម្លាប់ បង្ខំឱ្យធ្វើការដូចជា "សត្វធាតុ" ដោយមិនខ្វល់ពីអាយុរបស់ពួកគេ រារាំងមិនឱ្យបរិភោគផលដែលបានមកពីកម្លាំងពលកម្មរបស់ពួកគេ ហើយមិនត្រូវបានអនុញ្ញាតឱ្យមានកម្មសិទ្ធិលើទ្រព្យសម្បត្តិ? គាត់ក៏បានសួរថា ហេតុអ្វីបានជាខ្មែរក្រហម មិនបានសាងសង់សាលាក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ហើយអ្វីខ្លះដែលខ្មែរក្រហមបានធ្វើជាមួយនឹងធនធានមនុស្សកម្ពុជា?

លោក **នួន ជា** បានជ្រើសយកមិនឆ្លើយសំណួរដោយសារតែការអស់កម្លាំងពេក។ លោក **ខៀវ សំផន** បានឆ្លើយតបទៅនឹងសំណួររបស់សាក្សី ដែលភាគច្រើនលើកឡើងវិញនូវការឆ្លើយតប ដែលគាត់ធ្លាប់បានផ្តល់ឱ្យទៅសាក្សីផ្សេងៗទៀត។ គាត់បានលើកឡើងថា គាត់មិនមានអំណាច ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្ម ដូចនេះក៏បានចូលរួមជាមួយខ្មែរក្រហម ក្នុងគោលបំណងផ្សះផ្សាកងកម្លាំងតស៊ូ បន្ទាប់ពីរដ្ឋប្រហារនៅឆ្នាំ ១៩៧០ និងដើម្បីទប់ស្កាត់សង្គ្រាមវៀតណាម កុំឱ្យហូរចូលមកក្នុងទឹកដីកម្ពុជា។ ទាក់ទងនឹងកង្វះស្បៀងអាហារអំឡុងពេលរបបខ្មែរក្រហម លោក **ខៀវ សំផន** បានទទួលស្គាល់ថា គាត់មានតួនាទីក្នុងការចែកចាយម្ហូបអាហារ និងបានអះអាងថា បានផ្ញើចេញ "រថយន្តដឹកស្បៀងអាហាររាប់រយ ឬ រាប់ពាន់គ្រឿង" ទៅទីកាន់ទីតាំងផ្សេងៗគ្នា។ ចំពោះការដោះស្រាយបញ្ហាការអប់រំ លោក **ខៀវ សំផន** បានកត់សម្គាល់ថា ក្រោមរបប **សម្តេចសីហនុ** មានតែមនុស្សមួយចំនួនតូចតែប៉ុណ្ណោះ បានទទួលការអប់រំ។ ហេតុដូច្នេះ ខ្មែរក្រហមបានសម្រេចចិត្តថា ការអប់រំឱ្យបានទូលំទូលាយ គឺមិនល្អប្រសើរនោះទេនៅពេលនោះ ហើយយុវជនត្រូវបានអប់រំជំនួសវិញតាមរយៈការធ្វើការនៅក្នុងរោងចក្រ ឬដើររើសដី។ បើទោះបីជាលោក **ខៀវ សំផន** បានថ្លែងថា កម្មវិធីអប់រំ មានគោលបំណងនឹងធ្វើឡើង បន្ទាប់ពីការលូតលាស់របស់ប្រទេសជាតិ គាត់ក៏បានទទួលស្គាល់ថា បានលឺ **ប៉ុល ពត** សួរថាតើការរីកចម្រើនផ្នែកវិស័យអប់រំ គួរត្រូវកាត់បន្ថយឬយ៉ាងណា ប៉ុន្តែ គាត់បានបន្ថែមថា នេះមិនបានមានន័យថា "គ្មានសាលារៀនទាំងអស់នោះទេ"។

## *ឃ.៦. ឥរិយាបថរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន*

លោក **យស ផល** បានបាត់បង់ភាពអត់ធ្មត់របស់គាត់ ហើយបានជូតទឹកភ្នែករបស់គាត់ នៅពេលគាត់បានរៀបរាប់អំពីការរងទុក្ខលំបាក ដែលគាត់បានស៊ូទ្រាំក្នុងអំឡុងពេលជម្លៀសប្រជាជនចេញ។ បើទោះបីជាឱកាសមួយនៅពេលដែលសាក្សី បានទទួលរងការភិតភ័យបន្ទាប់ពីត្រូវបានសួរសំណួរដដែលៗ ដោយមេធាវីការពារក្តីលោក **នួន ជា** គឺ លោក **វ៉ិចទ័រ កូប៉េ (Mr. Victor Koppe)** សាក្សីបានឆ្លើយតបយ៉ាងអត់ធ្មត់ទៅកាន់សំណួរទាំងអស់ ដែលបានចោទសួរទៅកាន់គាត់។ (សូមមើលផ្នែកទី ៣.គ)

## ង. សក្ខីកម្មរបស់អ្នកស្រី ធុច ផាន់ដារា (TCPP-156)

អ្នកស្រី **ធុច ផាន់ដារា**[9] មានអាយុ ៦៩ឆ្នាំ គឺជាដើមបណ្តឹងរដ្ឋប្បវេណីទីមួយ ដែលបានផ្តល់សក្ខីកម្មនៅថ្ងៃពុធ។ អ្នកស្រីបានផ្តល់សក្ខីកម្មអំពីការរងទុក្ខវេទនាដែលអ្នកស្រីបានជួបប្រទះនៅអំឡុងពេលកម្ពុជា

ប្រជាធិបតេយ្យ ដោយរួមបញ្ចូលទាំងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយនិងការជម្លៀសជាបន្ត បន្ទាប់ទៅកាន់ខេត្តពោធិ៍សាត់។

### *ង.១. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

សាក្សីបានចាំថា ប្រជាជនចូលរួមអបអរសាទរលើកដំបូង នៅពេលដែលខ្មែរក្រហមបានចូលទីក្រុង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ទោះជាយ៉ាងណាក៏ដោយ ភ្លាមៗបន្ទាប់ពីទាហានខ្មែរក្រហមបានប្រាប់ ប្រជាជនថា ពួកគេត្រូវតែចាកចេញពីផ្ទះសម្បែងរបស់ពួកគេ ដើម្បីឱ្យរដ្ឋាភិបាលបានសម្អាតទីក្រុង និង ជៀសវាងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក។ សាក្សី និងឪពុកម្ដាយដែលរស់នៅក្នុងអគារដូចគ្នា នោះ បានស្ទាក់ស្ទើរក្នុងការចាកចេញពីផ្ទះរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីពួកទាហានបាន ចូលក្នុងផ្ទះ ហើយបានប្រាប់ពួកគេយ៉ាងគេឱ្យរៀបចំបង្វិចសម្រាប់រយៈពេលបីថ្ងៃ សាក្សីបានចាកចេញតាម ឡានពីរគ្រឿងជាមួយគ្រួសាររបស់នាង ដោយប្អូនស្រីរបស់សាក្សីបានជិះកង់តាមពីក្រោយ។ អ្នកស្រី បាន រម្លឹកថា តាមដងផ្លូវពោរពេញទៅដោយមនុស្ស ស្ទើរតែមិនអាចទៅមុខរួច។ ទោះជាយ៉ាងណាក៏ដោយ ពួកគេ បានទៅដល់ផ្លូវទៅកាន់ខេត្តព្រះសីហនុនៅពេលល្ងាចនោះ។ នៅពេលនោះ អ្នកស្រី បានឮស្នូរកាំភ្លើងបាញ់ ភ្លាមៗ បន្ទាប់ពីឡាន និងកង់ ត្រូវបានរឹបអូស ហើយពួកគេត្រូវបានអនុញ្ញាតឱ្យយកតែទឹក និងអង្ករទៅ ជាមួយតែប៉ុណ្ណោះ។ អ្នកស្រី **ធុច ផាន់ដារា** បានថ្លែងថា វាកាន់តែច្បាស់ឡើងសម្រាប់ពួកគេត្រង់ថា "រឿងរ៉ាវ នឹងកាន់តែធ្ងន់ធ្ងរទៅៗ" ហើយពួកគេមិនបានធ្វើការតស៊ូអ្វីទេ នៅពេលដែលខ្មែរក្រហម បានរឹបអូសយក មធ្យោបាយដឹកជញ្ជូនរបស់ពួកគេនោះ។ សាក្សី និងគ្រួសារ បានធ្វើដំណើរឆ្ពោះទៅកាន់គីឡូម៉ែត្រលេខ១៣ ជាទីកន្លែងដែលពួកគេមានដីតូចមួយកន្លែង។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានស្នាក់នៅទីនោះតែមួយ យប់ប៉ុណ្ណោះ មុនពេលដែលទាហានខ្មែរក្រហមបានមកដល់ និងបង្ខំឱ្យពួកគេធ្វើដំណើរទៅមុខជាមួយប្រជា ជនដ៏ច្រើនសន្ធឹកសន្ធាប់។ នៅក្នុងអំឡុងពេលធ្វើដំណើរនេះ អ្នកស្រី **ធុច ផាន់ដារា** បានឃើញស្ត្រីម្នាក់ឆ្លងទន្លេ នៅតាមផ្លូវ មនុស្សម្នាក់ពុងត្រូវបានរុញនៅតាមផ្លូវនៅស្អិតនៅលើគ្រែរបួសដែលមានព្យួរស៊ីរ៉ូម ហើយកុមារ ត្រូវបង្ខំឱ្យព្រាត់ប្រាស់ចោលឪពុកម្ដាយរបស់ពួកគេ។

ក្រុមគ្រួសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី បានបន្តការធ្វើដំណើររបស់ពួកគេរហូត ហើយបានមកដល់ ភូមិមួយឈ្មោះថា ភូមិកំពង់មាស។ អ្នកស្រី មិនសូវជាចាំបានថា អ្នកស្រីបានស្នាក់នៅក្នុងភូមិនោះរយៈពេល ប៉ុន្មានខែនោះទេ ដោយសារតែ "ពេលវេលាសឹងតែមិនកើតឡើង"។ មុនពេលចូលក្នុងភូមិ សាច់ញាតិរបស់ ពួកគេបានរម្លឹកឲ្យបំផ្លាញអត្តសញ្ញាណប័ណ្ណ និងដូរឈ្មោះរបស់ពួកគេចេញ។ សាក្សី បានដាក់ឈ្មោះខ្លួនឯង ថា **"តែន"** ជាឈ្មោះក្លែងក្លាយរបស់អ្នកស្រី។ ពេលព្រឹកឡើង ពួកគេបានមកដល់ ក៏ត្រូវបានដាក់ការងារឱ្យ ធ្វើភ្លាមៗ។ អ្នកស្រី **ធុច ផាន់ដារា** បានប្រាប់ទៅតុលាការថា បុរសៗត្រូវបានគេតម្រូវឱ្យធ្វើនៅខាងក្រៅភូមិ ហើយអាចវិលត្រឡប់មកវិញជារៀងរាល់ ១០ថ្ងៃម្ដង។ ពួក "ប្រជាជនថ្មី" ត្រូវបានតាមដានដោយគិញ។ បើ ទោះបីជាសាក្សីបាននិយាយថា អ្នកស្រីបានទទួលអង្ករ និងដំឡូងមី សម្រាប់បរិភោគក៏ដោយ ក៏អ្នកស្រីមិន បានបរិភោគអាហារមានជាតិប្រូតេអ៊ីនណាមួយនោះទេ។

### ង.២. ការជម្លៀសប្រជាជនចេញជាបន្តបន្ទាប់

បន្ទាប់ពីរយៈពេលជាច្រើនខែនៅក្នុងភូមិកំពង់មាស សាក្សីបានផ្តល់សក្ខីកម្មថា អ្នកស្រី និងគ្រួសាររបស់អ្នកស្រី ត្រូវបានជម្លៀសចេញជាលើកទីពីរទៅកាន់ខេត្តពោធិ៍សាត់។ ដំបូងពួកគេបានឡើងជិះរថយន្តទៅខេត្តកំពង់ឆ្នាំង បន្ទាប់មកជិះរថភ្លើង "ពោរពេញទៅដោយមនុស្សណែនតាន់តាប់" ហើយចុងក្រោយបានទៅដល់ភ្នំជានិតវិញ។ ហើយនេះគឺជាកន្លែងដែល "គ្រោះថ្នាក់អត់អាហារបានចាប់ផ្តើម" បើយោងទៅតាមអ្នកស្រី **ធុច ផាន់ដារា**។ អ្នកមកដល់ថ្មី ត្រូវបានប្រាប់ឲ្យសាងសង់ខ្ទមខ្លួនឯង ហើយត្រូវយកឥវ៉ាន់របស់ពួកគេទៅដោះដូរយកកាំបិតដើម្បីបំពេញកិច្ចការរបស់ពួកគេ។ សាក្សី បានលើកឡើងថា ពួកគេត្រូវបានចាត់តាំងឱ្យទៅធ្វើការងារធ្ងន់ធ្ងរដោយមានអាហារតិចតួច និងបានរម្លឹកទៅដល់ការឈឺចាប់ដែលអ្នកស្រីបានរងនូវទុក្ខវេទនា ដោយបានឃើញឪពុករបស់អ្នកស្រីបានអូសរទេះគោតែម្នាក់ឯង។ ឆ្នាំ១៩៧៦ អ្នកស្រី **ធុច ផាន់ដារា** បាននិយាយថា មនុស្សចាប់ផ្តើមស្លាប់ក្នុងចំនួនមួយដ៏ច្រើន រួមទាំងសមាជិកគ្រួសាររបស់អ្នកស្រីផងដែរ។ ដើមបណ្តឹងរដ្ឋប្បវេណី បានរម្លឹកដល់របៀបដែលកូនប្រុសរបស់គាត់បានស្លាប់ បន្ទាប់ពីបានកើតជំងឺរលាកខួរក្បាល ហើយពួកគេគ្មានថ្នាំប៉េនីស៊ីលីនដើម្បីព្យាបាលគាត់នោះទេ។

### ង.៣. ការស្វែងរក និងការសម្លាប់អតីតមន្ត្រី លន់ នល់

សាក្សី បានចងចាំថា នៅក្នុងខេត្តពោធិ៍សាត់ គ្រួសាររបស់អ្នកស្រីត្រូវបានគេចោទប្រកាន់ ហើយត្រូវបាននាំខ្លួន រួមជាមួយក្រុមគ្រួសារចំនួនប្រាំផ្សេងទៀត ដើម្បីទៅកាន់បឹងកន្ទួត។ បន្ទាប់ពីត្រូវបានចោទសួរអំពីជីវប្រវត្តិរបស់ពួកគេពេញមួយព្រឹក ក្រុមគ្រួសាររបស់សាក្សីនៅទីបំផុតត្រូវបានដោះលែង និងផ្តល់ត្រីងៀត និងអង្ករ។ គ្រួសាររបស់សាក្សីបានបន្តថា ពួកគេគឺជាអ្នកលក់ដូរ មុនពេលពួកគេបានក្លាយជាកសិករ។ បើទោះបីជា សាក្សីបានរម្លឹកពីភាពសប្បាយចិត្តនឹងការទទួលបានអាហារក៏ដោយ អ្នកស្រី ក៏បានចងចាំនូវអារម្មណ៍ប្រុងប្រយ័ត្ន ពីព្រោះតែអ្នកស្រីបានឮរឿងរ៉ាវថា មនុស្សដែលគេឱ្យអាហារញ៉ាំ ក្រោយមកនឹងត្រូវបានគេយកទៅសម្លាប់ចោល។ ទោះជាយ៉ាងណាក៏ដោយ រឿងនេះមិនបានកើតឡើងទេ ហើយក្រុមរបស់អ្នកស្រីត្រូវបានដោះលែង។

ក្នុងអំឡុងពេលសាកសួរដោយសហព្រះរាជអាជ្ញាអន្តរជាតិលោក **ឃីត រេយ័ន័រ (Mr. Keith Raynor)** សាក្សីក៏បានប្រាប់អង្គជំនុំជម្រះ អំពីការសម្លាប់ឧត្តមសេនីយ៍របស់ **លន់ នល់** ឈ្មោះ **ថាច់ សារី (Thach Sary)** ដែលត្រូវជាបងប្អូនជីដូនមួយរបស់អ្នកស្រីតាមរយៈការរៀបអាពាហ៍ពិពាហ៍។ សាក្សីបានប្រាប់តុលាការថា បងប្អូនជីដូនមួយរបស់អ្នកស្រីឈ្មោះ **ឃួន** បានជូនដំណឹងអ្នកស្រីថា **ថាច់ សារី** ត្រូវបានសម្លាប់បន្ទាប់ពីបានបង្ហាញខ្លួនឯងដល់ខ្មែរក្រហមនៅឯក្រសួងព័ត៌មាន។

### ង.៤. សំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី សួរទៅកាន់សហជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណី បានចោទសួរសំណួរពីរ ទៅកាន់សហជនជាប់ចោទ។ សំណួរទីមួយសួរថា ហេតុអ្វីបានជាខ្មែរក្រហម "សង្កត់" ទៅលើប្រជាជន១៧ មេសា និងទីពីរ តើអ្វីទៅជាគោលបំណងនៃស្វ័យទិតៀន?

លោក **ខៀវ សំផន** បានយល់ពីទុក្ខព្រួយរបស់គាត់ បន្ទាប់ពីបានស្ដាប់ពីរឿងរ៉ាវនៃការឈឺចាប់របស់សាក្សី។ បន្ទាប់មក គាត់បានបន្តពន្យល់ពីចម្លើយនៃសំណួរទាំងពីរនេះ ដែលមានការពាក់ព័ន្ធនឹងការតស៊ូដើម្បីវណ្ណៈមនោគមន៍ បើទោះបីជា ខ្លួនគាត់ផ្ទាល់មិនមែនជា "ជនមនោគមន៍វិជ្ជានិយម" នៃរបបកម្ពុជាប្រជាធិបតេយ្យ។ តាមរយៈការចូលរួមរបស់គាត់នៅក្នុងបក្សកុម្មុយនីស្ត គាត់បានឲ្យដឹងថា បក្សកុម្មុយនីស្តកម្ពុជា បានរៀបគម្រោងជាពីរដំណាក់កាលនៃបដិវត្តន៍ដើម្បីឱ្យកើតឡើង គោលបំណងទីមួយ គឺបដិវត្តន៍ជាតិប្រជាធិបតេយ្យដើម្បីរំដោះប្រទេសកម្ពុជាពីអាណានិគមនិយមបារាំង និងពួកចក្រពត្តិនិយមអាមេរិក និងគោលបំណងទីពីរគឺ "ដំណាក់កាលបដិវត្តន៍សង្គមនិយម" មានគោលបំណងលុបចោលទ្រព្យសម្បត្តិឯកជន ដើម្បីឱ្យមានការរីកចម្រើនឆាប់រហ័សដើម្បីសាងសង់ ទំនប់ ប្រឡាយ និងការដាំដុះស្រូវ ដើម្បីចិញ្ចឹមប្រជាជន។ លោក **ខៀវ សំផន** បានសម្ដែង "ការភ្ញាក់ផ្អើល" ខណៈឮអំពីការសាងសង់ទំនប់ និងប្រព័ន្ធប្រឡាយដែលបាននាំឱ្យ "មានការបាត់បង់" បែបនេះ។ ទាក់ទងទៅនឹង ការស្វ័យទិតៀន លោក **ខៀវ សំផន** បានពន្យល់ថា វាជាវិធានការក្នុងការកសាងសមាជិកបក្សកុម្មុយនីស្តគំរូមួយ។ លោកបានបន្ថែមថា គាត់ក៏ត្រូវបានតម្រូវឱ្យចូលរួមក្នុងស្វ័យទិតៀនដែរ។ ទោះជាយ៉ាងណាក៏ដោយ គាត់មិនដែលទទួលបានជោគជ័យពេញលេញទេ ដោយសារតែចិត្តគំនិតរបស់គាត់ គឺនៅតែជា "អ្នកមូលធននិយមពាក់កណ្ដាល" ហើយគាត់នៅតែស្រឡាញ់សមាជិកគ្រួសារ ជំនួសឱ្យការលះបង់អ្វីគ្រប់យ៉ាង ហើយផ្ដោតទៅលើជាតិ។

លោក **នួន ជា** ក៏បានឆ្លើយតបទៅនឹងសំណួររបស់សាក្សី បើទោះជាសុខភាពរបស់គាត់ មិនមានភាពប្រសើរសោះ។ បន្ទាប់ពីការសម្ដែងនូវការគោរពទៅកាន់អ្នកស្លាប់ និងអ្នកដែលបានបាត់បង់ក្រុមគ្រួសារក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ លោកក៏បានពន្យល់ថាៈ "រឿងរ៉ាវមានភាពស្មុគស្មាញ" ហើយថ្នាក់អ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ "មិនមែនល្អឥតខ្ចោះ" នោះទេ។ បន្ទាប់មក លោកបានរៀបរាប់ឡើងវិញអំពីការស្លាប់ ការជម្លៀសប្រជាជន និងការរងទុក្ខវេទនា ដែលសមាជិកនៃគ្រួសារផ្ទាល់របស់គាត់បានជួបប្រទះ។ ការឆ្លើយទៅនឹងសំណួរទាំងនេះ លោក **នួន ជា** បានបដិសេធថា ខ្លួនមិនដែលធ្លាប់បានស្នើសុំឱ្យមានការប្រព្រឹត្តខុសគ្នាទៅលើប្រជាជនចាស់ និងប្រជាជនថ្មីនោះទេ។ ទាក់ទងទៅនឹងស្វ័យទិតៀន លោក **នួន ជា** បានពន្យល់ថា គោលបំណង គឺដើម្បីលុបបំបាត់ "សមាសភាពអាក្រក់" របស់មនុស្សម្នាក់ និងដើម្បីលើកទឹកចិត្តដល់ការយល់ដឹងអំពីគោលបំណងនៃការកសាងអ្នកសង្គមនិយម។

ក្រោយមក ដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើឱ្យលោក **ខៀវ សំផន** បួងសួងជាមួយអ្នកស្រី ឲ្យព្រលឹងអ្នកដែលបានលាចាកលោក។ លោក **ខៀវ សំផន** បានឆ្លើយតបថា លោកមិនត្រឹមតែបួងសួងដល់ប្រជាជនកម្ពុជាដែលបានរងទុក្ខនោះទេ ប៉ុន្តែថែមទាំងបួងសួងដល់ "យោធិនក្លាហាន" ដែលបានប្រឈមមុខនឹងគ្រាប់បែក B-៥២ ដើម្បីរំដោះទីក្រុងភ្នំពេញ។

### *ង.៥. ទុក្ខវេទនា និងព្យសនកម្ម ដោយសារឧក្រិដ្ឋកម្មនៅក្នុងករណី ០០២*

អ្នកស្រី **ធុច ផាន់ដារា** បានប្រាប់អង្គជំនុំជម្រះពីរបួសផ្លូវចិត្ត ដែលអ្នកស្រីបានស៊ូទ្រាំបន្ទាប់ពីឃើញឪពុកម្ដាយរបស់អ្នកស្រី បានស្លាប់នៅក្នុងស្ថានភាពមួយដែល "អាក្រក់ជាងសត្វ"។ ដើមបណ្ដឹងរដ្ឋប្បវេណី បានឈឺចាប់ដោយសារពិរុទ្ធភាពរបស់អ្នករស់រានមានជីវិត ត្រូវលងបន្លាចដោយអារម្មណ៍ដែលអ្នកស្រីខកខានមិនបានសង្គ្រោះជីវិតឪពុកម្ដាយរបស់អ្នកស្រី។ អ្នកស្រី ក៏បានរៀបរាប់ឡើងវិញអំពីការតស៊ូរបស់

អ្នកស្រី បន្ទាប់ពីផ្លាស់ទៅកាន់ប្រទេសបារាំងក្នុងនាមជាជនភៀសខ្លួនជាមួយនឹងប្អូនស្រីរបស់អ្នកស្រីក្នុងឆ្នាំ ១៩៧៩។ អ្នកស្រីបានប្រាប់តុលាការ "ពីស្ថានភាពរស់នៅម្នាក់ឯងដ៏គួរឱ្យភ័យខ្លាច" ដែលអ្នកស្រីបានជួប ប្រទះនៅទីនោះ និង របៀបដែលអ្នកស្រីបានក្លាយជាអ្នកស្រេកឃ្លានអាហារដែលអត់មិនបាន និងបាន ចំណាយពេលបីខែនៅក្នុងមន្ទីរពេទ្យចិត្តសាស្ត្រ។ អ្នកស្រី បានអះអាងថា សក្ខីកម្មរបស់អ្នកស្រីបានជំរុញ ដល់ដំណើរស្វែងរកយុត្តិធម៌ ខណៈដែលអ្នកស្រីមានអារម្មណ៍ថា វាជាវិធីតែមួយគត់ដើម្បីធានាសន្តិភាព និង ស្មារតិក្តិយសរបស់ឪពុកម្តាយរបស់អ្នកស្រី ។

### *ង.៦. ឥរិយាបថរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន*

អ្នកស្រី មានអារម្មណ៍រំជួលចិត្តក្នុងអំឡុងពេលផ្តល់សក្ខីកម្ម ជាពិសេសនៅពេលដែលរម្លឹកឡើងវិញ អំពីការស្លាប់របស់ឪពុកម្តាយ និងកូនប្រុសរបស់អ្នកស្រី។ នៅចំពេលមួយ អ្នកស្រីបានបញ្ឈប់ផ្តល់សក្ខីកម្ម ដើម្បីរកនឹកខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយ សក្ខីកម្មដែលអ្នកស្រីបានផ្តល់ គឺមានភាពច្បាស់លាស់ ហើយបើទោះបីជាអ្នកស្រីមានបញ្ហាក្នុងការកំណត់ពេលវេលា ដែលអ្នកស្រីស្នាក់នៅកន្លែងនីមួយៗនៅក្នុង អំឡុងពេលដំណាក់កាលទីមួយ និងទីពីរនៃការជម្លៀសប្រជាជនក៏ដោយ។ អ្នកស្រីមានភាពច្បាស់លាស់ និង ស៊ីចង្វាក់ទៅនឹងព្រឹត្តិការណ៍តាមលំដាប់លំដោយនៃការជម្លៀស និងទិដ្ឋភាពផ្សេងទៀតនៃសក្ខីកម្មរបស់អ្នក ស្រី។

## ច. **សក្ខីកម្មរបស់អ្នកស្រី ចាន់ សុជាតិ (TCPP-7)**

ដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី **ចាន់ សុជាតិ**[10] អាយុ ៥៦ ឆ្នាំ ជាកសិករ បច្ចុប្បន្នកំពុងរស់នៅ ខេត្ត ពោធិ៍សាត់ បានផ្តល់រឿងរ៉ាវលម្អិតនៃការលំបាក ដែលអ្នកស្រីធ្លាប់មានបទពិសោធន៍ធ្វើការក្នុងផ្នែកមួយនៃ អង្គភាពចល័តនៅក្នុងស្រុកមោងឫស្សី។ សាក្សី បានបាត់បង់សមាជិកគ្រួសារចំនួន ១៤នាក់ ក្នុងអំឡុងពេល របបនេះ ដោយសារតែធ្វើពលកម្មធ្ងន់ធ្ងរ "អមនុស្សធម៌" និងការខ្វះស្បៀងអាហារ។

### *ច.១. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោង ៩ព្រឹក អ្នកស្រី **ចាន់ សុជាតិ** និងគ្រួសាររបស់អ្នកស្រី ១៥នាក់ ត្រូវបានបង្ខំឱ្យចេញពីទីក្រុងភ្នំពេញ។ ទាហានខ្មែរក្រហម បានប្រាប់ពួកគាត់ថា ឲ្យចាកចេញពីតែបី ថ្ងៃប៉ុណ្ណោះ ដើម្បីទុកពេលឱ្យខ្មែរក្រហមបោសសម្អាតសត្រូវចេញពីទីក្រុង ហើយក៏ដើម្បីឱ្យប្រជាជនគេច ចេញពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកដែរ។ សាក្សី និងគ្រួសារ បានចាកចេញពីលំនៅដ្ឋានរបស់ ពួកគេភ្លាម ដោយយកតែម៉ូតូ កង់ និងទឹក សម្រាប់ប្អូនៗរបស់អ្នកស្រី។ នៅតាមផ្លូវ អ្នកស្រី មានការភ្ញាក់ ផ្អើលជាខ្លាំងដោយឃើញមនុស្សរកកុញបានធ្វើដំណើររួមគ្នា ដែលរួមមានទាំងអ្នកឈឺបន្ទោងស៊ីរ៉ូមជាប់នៅនឹង ដៃរបស់ពួកគេ។ អ្នកស្រី ក៏បានឃើញសាកសពមួយចំនួននៅតាមដងផ្លូវ។ សាក្សី និងគ្រួសារបានសម្រេច ចិត្តស្នាក់នៅក្នុងវត្តនិរោធ ដោយមានបំណងត្រឡប់មកផ្ទះវិញបន្ទាប់ពីរយៈពេលបីថ្ងៃបានកន្លងផុតទៅ។ ទោះជាយ៉ាងណាក៏ដោយ ពួកខ្មែរក្រហម បានបង្ខំឱ្យពួកគេផ្លាស់ទីបន្តទៀតទៅកាន់ស្រុកកៀនស្វាយ ដែល ពួកគេបាននៅទីនោះរយៈពេលប្រាំមួយខែ។ សាក្សី បានលើកឡើងថា គ្មានអាហារគ្រប់គ្រាន់ ហើយប្អូនស្រី របស់អ្នកស្រី បានស្លាប់ដោយសារញ៉ាំបបររាវជំនួសឱ្យទឹកដោះ។

### ច.២. ការជម្លៀសប្រជាជនជាលើកទី២ ទៅកាន់ស្រុកមោងឫស្សី

ប្រហែលជាប្រាំមួយខែបន្ទាប់ពី សាក្សី និងគ្រួសារ បានទៅដល់ស្រុកកៀនស្វាយ ថ្នាក់ដឹកនាំអង្គការក្នុងតំបន់បានប្រកាសថា អ្នកដែលត្រូវគេជម្លៀសពីភ្នំពេញអាចវិលត្រឡប់ទៅទីក្រុងវិញបាន។ នៅវេលាម៉ោង ៥រសៀល អ្នកស្រី និងគ្រួសារ បានឡើងកប៉ាល់ជាមួយនឹងមនុស្សរាប់រយនាក់ផ្សេងទៀត ដើម្បីឆ្ពោះទៅកាន់ទីក្រុង។ នៅពេលដែលកប៉ាល់បានឆ្លងកាត់ព្រះបរមរាជវាំង អ្នករាល់គ្នាបានស្រែកអបអរសាទរ ហើយបុរសម្នាក់បានស្រែក "[ ជ] យោ ឥឡូវនេះ យើងមកដល់រាជធានីភ្នំពេញហើយ"។ សាក្សី បានចាំថា ទាហានខ្មែរក្រហម បានហៅបុរសម្នាក់នោះមក ហើយបាញ់គាត់។ បន្ទាប់ពីហ្នឹងមក មនុស្សគ្រប់គ្នានាំគ្នាស្ងាត់។

កប៉ាល់ បានមកដល់ខេត្តកំពង់ឆ្នាំងនៅពេលព្រឹកព្រលឹម ហើយសាក្សីបានចាំថា អង្ករមួយកំប៉ុង ត្រូវបែងចែកទៅរាល់មនុស្សបីនាក់។ បន្ទាប់មក អ្នកស្រីក៏បានធ្វើដំណើរតាមរថភ្លើងទៅភូមិព្រៃទទឹង ស្រុកមោងឫស្សី ។ បើយោងតាមការចងចាំរបស់សាក្សីនៅពេលនោះ ភូមិនានាមានទំហំតូចជាងព្រៃដោយមានតែផ្ទះបីខ្ទង់ប៉ុណ្ណោះ បានសង់ឡើងសម្រាប់ទាហានស្រុក។ ទាហាន បានប្រាប់អ្នកមកដល់ថ្មីឱ្យឆ្ការព្រៃ និងសង់ផ្ទះរបស់ពួកគេខ្លួនឯង។ នៅភូមិនេះ ប្រជាជនត្រូវបានគេបញ្ជាឱ្យធ្វើការ និងបរិភោគជារួម។ សាក្សី និងប្អូនស្រីបានធ្វើការនៅអង្គភាពស្ត្រី ហើយប្អូនៗរបស់អ្នកស្រី បានធ្វើការនៅក្នុងអង្គភាពយុវជន។ នៅពេលមួយអំឡុងពេលស្នាក់នៅរបស់អ្នកស្រីនៅភូមិព្រៃទទឹង អ្នកស្រី **ចាន់ សុជាតិ** ត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅអង្គភាពចល័ត។

### ច.៣. បទពិសោធន៍ការងារនៅក្នុងស្រុកមោងឫស្សី

អ្នកស្រី **ចាន់ សុជាតិ** បានផ្តល់សក្ខីកម្មពីស្ថានភាពលំបាក ដែលអ្នកស្រីបានជួបប្រទះ ពេលកំពុងធ្វើការនៅក្នុងអង្គភាពចល័ត។ ខណៈដែលកំពុងធ្វើការនៅក្នុងអង្គភាពនេះ អ្នកស្រីត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅក្រុមគ្រួសារជារៀងរាល់ ១០ថ្ងៃម្តងតែប៉ុណ្ណោះ។ នៅការដ្ឋានការងារនីមួយៗ អ្នកស្រីបានចាំថា សមាជិករបស់អង្គភាព ត្រូវតែសម្រេចឱ្យបាននូវចំនួនកូតាដែលបានដាក់ឱ្យ មុនពេលពួកគេទទួលបានបបររាវពីរវែក។ ខកខានមិនបំពេញតាមចំនួនកូតានៃការងារ ក៏អាចនឹងនាំឱ្យទទួលរងការវាយដំ និង/ឬ ការចោទប្រកាន់ថាជាសត្រូវមកពីវៀតណាម ឬ ជាពួកសក្តិភូមិ។ សាក្សី បានលើកឡើងថា ប្រជាជនធ្វើការក្រោមការគំរាមកំហែង និងត្រូវបានជំរុញឱ្យទៅធ្វើ "ហួសពីសមត្ថភាពរបស់មនុស្សដោយធ្វើការងារធ្ងន់ធ្ងរ។" អ្នកស្រី ក៏បានចាំថា បានឃើញសាកសពជាច្រើននៅពេលធ្វើដំណើរពីកន្លែងការងារទៅកាន់ផ្ទះ។

នៅចំណុចមួយ ដើមបណ្តឹងរដ្ឋប្បវេណី បានសម្រេចចិត្តរត់ចេញជាមួយនឹងប្អូនស្រី ដែលធ្វើការនៅការដ្ឋានជាមួយគ្នានោះ។ អ្នកស្រី បានប្រាប់ប្រធានអង្គភាពថា ពួកគេនឹងទៅប្រមូលសម្លៀកបំពាក់ដើម្បីធ្វើអង្រឹង ហើយបានទទួលអង្ករបីកំប៉ុង សម្រាប់ការធ្វើដំណើរនេះ។ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីរកប្អូនស្រីរបស់អ្នកស្រីមិនឃើញនៅកន្លែងដែលពួកគេបានរៀបចំដើម្បីជួបគ្នានោះ អ្នកស្រី **ចាន់ សុជាតិ** បានត្រឡប់មកផ្ទះវិញដើម្បីស្វែងរកម្តាយរបស់អ្នកស្រីនៅផ្ទះ។ អ្នកស្រី មិនអាចរកឃើញម្តាយរបស់អ្នកស្រីទេ ហើយបានទៅមន្ទីរពេទ្យ បន្ទាប់ពីមានអារម្មណ៍ថាឈឺ។ នៅទីនោះ អ្នកស្រីបានជួបម្តាយរបស់គាត់ ដែលមានរាងកាយហើម ហើយស្ថិតនៅក្នុងស្ថានភាពដុនដាប។ អ្នកស្រី **ចាន់ សុជាតិ** បានសម្រេចចិត្តចាកចេញពី

មន្ទីរពេទ្យ ប៉ុន្តែ បានស្នាក់នៅក្បែរនោះ ដើម្បីបានពិនិត្យមើលស្ថានភាពម្ដាយរបស់គាត់។ អ្នកស្រី បានលួចអាហារបរិភោគដើម្បីរស់ ហើយនៅពេលខ្លះអ្នកស្រី មិនអាចទ្រាំនឹងការអត់ឃ្លានបានយូរ អ្នកស្រីក៏បានសុំការអនុញ្ញាតពីប្រធានអង្គភាព ធ្វើដំណើរទៅជួបពូរបស់ខ្លួន។ ប្រធានអង្គភាព បានហាមឃាត់អ្នកស្រីមិនឱ្យចេញទៅណាទេ។ មានពេលមួយ ដើមបណ្ដឹងរដ្ឋប្បវេណីបានចាំថា បានជួប **តាម៉ុក** ដែលកំពុងតែជិះកង់នៅជិតនោះ។ អ្នកស្រីក៏បានស្នើសុំអាហារពី **តាម៉ុក** ហើយគាត់បានបញ្ជាប្រធានអង្គភាពឱ្យផ្ដល់អាហារទៅឱ្យអ្នកស្រី ហើយប្រកាសថា មនុស្សគ្រប់រូបគឺស្ថិតនៅក្រោម "ដំបូលរបស់អង្គការ" ដូច្នេះ មិនគួរមានភាពខុសគ្នារវាងមនុស្ស។ បន្ទាប់មក សាក្សី ត្រូវបានគេឱ្យស៊ុប និងបាយ ហើយអ្នកស្រីបានចាំទៀតថា អ្នកស្រីមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលមេដឹកនាំមានអាហារបែបហ្នឹង ខណៈដែលអ្នកដទៃទៀតស្រេកឃ្លាន។

ដើមបណ្ដឹងរដ្ឋប្បវេណី បានប្រាប់ថា នៅឆ្នាំ១៩៧៦ របបអាហារត្រូវបានកាត់បន្ថយនៅសល់អង្ករបីកំប៉ុងសម្រាប់គ្រួសារទាំងមូល ដែលបានកាត់បន្ថយសមាជិកពី ១៥ ទៅ ១០នាក់។ អ្នកស្រី បានរម្លឹកទៅដល់ប្អូនស្រីរបស់គាត់ដែលបានស្លាប់ម្ដងមួយៗ និងការស្លាប់របស់ម្ដាយរបស់គាត់ ដែលអ្នកស្រីត្រូវបានរារាំងមិនឱ្យមកសួរសុខទុក្ខមុនពេលស្លាប់។ សាក្សី បានរម្លឹកទៅដល់ចំណុចមួយក្នុងអំឡុងពេលធ្វើការនៅក្នុងអង្គភាពចល័តថា អ្នកស្រីបានធ្លាក់ខ្លួនឈឺ ហើយត្រូវបានបញ្ជូនទៅផ្ទះក្រុមគ្រួសាររបស់អ្នកស្រី។ ថ្ងៃបន្ទាប់ អ្នកស្រីបាន ត្រឡប់ទៅកាន់ក្រុមគ្រួសារ ហើយបានឃើញថា ប្អូនបង្កើតពីរនាក់របស់អ្នកស្រីបានស្លាប់។ អ្នកស្រី បានរម្លឹកថា ពួកគេស្គមណាស់ ហើយបានញ៉ាំបាយផ្អម។ ពួកគេ មិនត្រូវបានអនុញ្ញាតឱ្យរើសយកអាហារតាមគំនរសម្រាមក្នុងព្រៃ ដើម្បីធ្វើជាអាហារបន្ថែមទៅលើរបបអាហារដែលបានកំណត់នោះទេ ហើយប្រសិនបើពួកគេត្រូវចាប់បាន ពួកគេនឹងត្រូវបានចាត់ទុកថាជាសត្រូវ និង "ត្រូវបានកម្ទេចចោល"។ អ្នកស្រី **ចាន់ សុជាតិ** បានលើកឡើងថា "វាជាសោកនាដកម្មមួយស្ថិតនៅក្រោមរបបខ្មែរក្រហម ដែលយើងត្រូវបង្អត់បាយ និងឱ្យម្ហូបអាហារបរិភោគដូចជាសត្វ"។

## *ច.៤. ការសួរសំណួររបស់ដើមបណ្ដឹងរដ្ឋប្បវេណី សួរទៅកាន់សហជនជាប់ចោទ*

អ្នកស្រី **ចាន់ សុជាតិ** បានសួរទៅកាន់សហជនជាប់ចោទថា ហេតុអ្វីបានជាខ្មែរក្រហម មានភាពឃោរឃៅយ៉ាងនេះម្ល៉េះ? ហើយបានជម្រុញឱ្យសហជនជាប់ចោទ សុំទោសទៅកាន់អ្នកស្លាប់ ដើម្បីអនុញ្ញាតឱ្យ "ព្រលឹងរបស់ពួកគេ បានទៅកាន់សុខគតិភព" លោក **ខៀវ សំផន** ដំបូងបានសម្ដែងនូវការភ្ញាក់ផ្អើលទៅលើសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការ ដោយលើកឡើងថា "អ្នកដែលបានប្រព្រឹត្តអំពើឃោរឃៅទាំងនោះ គឺមិនមែនជាប្រជាជនសាមញ្ញទេ ពួកគេជាមេដឹកនាំដែលគ្មានមេត្តាធម៌"។ លោក **នួន ជា** បានសង្កត់ធ្ងន់ថា គ្មានគោលនយោបាយសម្លាប់មនុស្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយគាត់បានសម្ដែងនូវការអាណិតអាសូរដល់អ្នកស្រី **ចាន់ សុជាតិ**។ គាត់មានជំនឿថា កម្ពុជាប្រជាធិបតេយ្យ "មានគោលបំណងល្អ" សម្រាប់ប្រទេសជាតិ។

## *ច.៥. ទុក្ខវេទនា និងព្យសនកម្ម ដោយសារឧក្រិដ្ឋកម្មនៅក្នុងករណី ០០២*

អ្នកស្រី បានចាំពីរបៀបដែលគាត់បានបាត់បង់សមាជិកនៃក្រុមគ្រួសារទាំងអស់ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រី បានប្រាប់តុលាការពីការឈឺចាប់ ដែលបានជម្រុញឱ្យគាត់តាំងនាមខ្លួន

ជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការស្វែងរកយុត្តិធម៌ ក្នុងនាមឲ្យក្រុមគ្រួសាររបស់គាត់ និង "ប្រជាជនកម្ពុជា"។ អ្នកស្រី បានសង្ឃឹមថា សក្ខីកម្មរបស់គាត់ នឹងជួយដល់តុលាការក្នុងការសម្រេចបាននូវគោលបំណងនោះ។

### *ច.៦. ឥរិយាបថរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន*

អ្នកស្រី **ចាន់ សុជាតិ** ដូចជាមានទុក្ខព្រួយនៅអំឡុងពេលផ្ដល់សក្ខីកម្មរបស់គាត់ ជាពិសេស នៅពេលអ្នកស្រី បានរៀបរាប់ឡើងវិញអំពីការស្លាប់របស់ក្រុមគ្រួសាររបស់អ្នកស្រី។ អ្នកស្រី ត្រូវបានគេសង្កេតឃើញថា យំនៅពេលសួរសំណួរទៅកាន់សហជនជាប់ចោទ។ នៅពេលខ្លះ វាមានភាពមិនច្បាស់លាស់នៅព្រឹត្តិការណ៍មួយចំនួន ដែលបានកើតឡើង។ ទោះជាយ៉ាងណាក៏ដោយ អង្គហេតុលម្អិតនៃរឿងរ៉ាវរបស់គាត់ ត្រូវបានបញ្ជាក់ដោយសំណួរដែលធ្វើឡើងដោយភាគី ជាពិសេសក្នុងអំឡុងពេលសួរសំណួរដោយសហព្រះរាជអាជ្ញាអន្តរជាតិលោក **វើយ័នវ៉រ**។

### ឆ. **សក្ខីកម្មរបស់អ្នកស្រី ហូ ចន្ថា** (TCPP-198)

អ្នកស្រី **ហូ ចន្ថា**[11] បានចូលមកឆ្លើយបំភ្លឺនៅថ្ងៃពុធពេលរសៀល។ ពាណិជ្ជករអាយុ ៦០ឆ្នាំរូបនេះ រស់នៅក្នុងភូមិពូកឫស្សី ខេត្តកណ្ដាល ប៉ុន្តែ មានស្រុកកំណើតនៅកំពង់សឹង្ហ។ សេចក្ដីថ្លែងការណ៍របស់អ្នកស្រីអំពីការរងទុក្ខវេទនា និងព្យសនកម្ម ត្រូវបានផ្ដោតលើការបាត់បង់សមាជិកក្រុមគ្រួសារចំនួន ២២ នាក់ នៅអំឡុងពេលរបបកម្ពុជា។ អ្នកស្រី ក៏បានផ្ដល់ពីជីវិតនៅក្នុងសហករណ៍ ជាពិសេស អ្វីដែលបានកើតឡើងចំពោះអ្នក ដែលខកខានមិនបានប្រគល់ទ្រព្យសម្បត្តិរបស់ពួកគេ។

### *ឆ.១. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

អ្នកស្រី បានប្រាប់តុលាការថា គាត់បានរស់នៅក្នុងគ្រួសារអ្នកមានទ្រព្យសម្បត្តិ និងបានរស់នៅក្នុង "ជីវិតដែលល្អ" មុនពេលដែលខ្មែរក្រហមបានឡើងកាន់អំណាច។ ក្រុមគ្រួសាររបស់អ្នកស្រី បានគ្រប់គ្រងទ្រព្យសម្បត្តិ និងបើកហាងលក់គ្រឿងទេសមួយនៅក្នុងទីក្រុងភ្នំពេញ។ នៅឆ្នាំ១៩៧២ អ្នកស្រីបានរៀបការជាមួយគ្រូបង្រៀនម្នាក់ ហើយពួកគេមានកម្មសិទ្ធលើទ្រព្យសម្បត្តិ និងរថយន្ត។ អ្នកស្រី បានកត់សម្គាល់ថា អ្នកស្រីមិនបានដឹងថា ការលំបាកនឹងមានន័យដូចម្ដេចទេនៅពេលនោះ។

ដើមបណ្ដឹងរដ្ឋប្បវេណី បានរម្លឹកពីការទទួលស្វាគមន៍ដល់ទាហានខ្មែរក្រហមនៅលើកដំបូង ពេលដែលខ្មែរក្រហម បានចូលដល់ទីក្រុងភ្នំពេញ។ តែយ៉ាងណា ពួកគេបានប្រាប់ប្រជាជន ឱ្យចាកចេញក្នុងរយៈពេលពីរបីថ្ងៃ ដើម្បីអនុញ្ញាតឱ្យពួកគេ "បោសសម្អាតទីក្រុង"។ សាក្សី និងក្រុមគ្រួសារ បានចាកចេញពីទីក្រុងភ្នំពេញតាមពោធិ៍ចិនតុង។ នៅក្នុងអំឡុងពេលជម្លៀសប្រជាជនចេញ អ្នកស្រីបានចាំពីការបំភ័យ និងការយល់ច្រឡំ បន្ទាប់ពីទាហានខ្មែរក្រហមបានបាញ់ជាច្រើនគ្រាប់ទៅលើមេឃ ដើម្បីគំរាមកំហែងពួកគេ។ អ្នកស្រី ក៏បានចាំថា បានឃើញសាកសពទាហាន **លន់ នល់** និងស្ត្រីដែលត្រូវបានគេបង្ខំឱ្យដើរ បន្ទាប់ពីសម្រាលកូនរួច។

អ្នកស្រី និងក្រុមគ្រួសារ បានរត់ទៅជ្រកកោនរយៈពេលមួយយប់ ហើយនៅពេលព្រឹកគ្រួសាររបស់គាត់ បានជិះទូកដើម្បីឆ្លងកាត់ទន្លេមួយ។ បន្ទាប់ពីដើរអស់រយៈពេល ១៥ថ្ងៃ គ្រួសាររបស់គាត់ បានមកដល់

ពូកឫស្សី។ នៅចំណុចមួយក្នុងអំឡុងពេលធ្វើដំណើរ ប្រជាជនស្រេកទឹកយ៉ាងខ្លាំងរហូតដល់ពួកគេបានផឹកទឹកកខ្វក់ពីស្រះទឹក ពីព្រោះ គ្មានទឹកស្អាតញ៉ាំទេ។

### ឆ.២. បទពិសោធន៍ការងារនៅក្នុងសហករណ៍ពូកឫស្សី

អ្នកស្រី បានរៀបរាប់ថា ជីវិតមានភាពវេទនាណាស់សម្រាប់ "ប្រជាជនថ្មី" នៅក្នុងសហករណ៍ពូកឫស្សី។ អ្នកស្រី និងក្រុមគ្រួសារ បានស្នាក់នៅក្នុងតំបន់នោះរហូតក្នុងរបបខ្មែរក្រហម។ អ្នកស្រី បានចាំថា ប្រជាជនត្រូវបានគេតម្រូវឱ្យធ្វើការកសិកម្មធ្ងន់ធ្ងរ ជាមួយអាហារតិចតួច ហើយមិនអាចរកថ្នាំព្យាបាលបាននោះទេ។ អ្នកស្រី ក៏បានរម្លឹកថា បន្ទាប់ពីឆ្លងទន្លេ គាត់ត្រូវបានបង្ខំឱ្យបន្តស្ទូង និងរង់ចាំជាច្រើនម៉ោងមុនពេលគាត់បានវិលត្រឡប់ទៅផ្ទះវិញដើម្បីបំបៅដោះកូន។ សាក្សី ក៏បាននិយាយអំពីការរើសអើង ដែលគាត់បានជួបប្រទះជាមនុស្សម្នាក់ក្នុងចំណោមប្រជាជន "១៧មេសា"។ នៅពេលមួយ នៅក្នុងខែមិថុនា ឆ្នាំ ១៩៧៥ ខណៈដែលធ្វើការក្នុងសហករណ៍ អ្នកស្រីបានចាំថា បងប្រុសថ្លៃរបស់គាត់ ត្រូវបានកោះហៅទៅចូលរួមក្នុងកិច្ចប្រជុំ ហើយមិនដែលត្រឡប់មកវិញទេ។

### ឆ.៣. ការដាក់ទណ្ឌកម្មចំពោះការលាក់ទ្រព្យសម្បត្តិឯកជន

បន្ទាប់ពីរបបខ្មែរក្រហមបានបញ្ចប់ អ្នកស្រី **ហូ ចន្ថា** បានសន្សំប្រាក់មួយចំនួន ហើយបានវិលត្រឡប់ទៅភូមិកំណើតជាមួយកូនរបស់គាត់ ដើម្បីស្វែងរកក្រុមគ្រួសារ។ អ្នកស្រីបានប្រាប់តុលាការថា អ្នកភូមិបានជូនដំណឹងថា ម្តាយ និងបងប្អូនបង្កើតចំនួនប្រាំនាក់ ត្រូវបានចាប់ខ្លួន និងសម្លាប់ដោយខ្មែរក្រហម បន្ទាប់ពីម្តាយរបស់នាងបានរត់ចេញពីមន្ទីរឃុំឃាំង។ ម្តាយរបស់អ្នកស្រី ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង ពីព្រោះតែគាត់ ត្រូវបានគេចោទប្រកាន់ពីបទរក្សាទុកមាស ហើយមិនប្រគល់ទៅឱ្យសហករណ៍។ ដើមបណ្តឹងរដ្ឋប្បវេណី បានប្រាប់តុលាការថា តើប្អូនប្រុសរបស់អ្នកស្រី និងប្រពន្ធរបស់គាត់ ត្រូវបានសម្លាប់ដោយខ្មែរក្រហមដោយរបៀបណា សម្រាប់ការខកខានមិនបានប្រគល់ទ្រព្យសម្បត្តិរបស់ពួកគេ ទៅសហករណ៍សម្រាប់ការប្រើប្រាស់ជាសមូហភាព។

### ឆ.៤. ទុក្ខវេទនា និងព្យសនកម្ម បណ្តាលមកពីបទឧក្រិដ្ឋក្នុងករណី ០០២

អ្នកស្រី បានខកចិត្តនៅពេលដែលរម្លឹកឡើងវិញដល់ការរងទុក្ខក្នុងអំឡុងពេលជម្លៀសប្រជាជន និងបទពិសោធន៍របស់គាត់រស់នៅក្នុងសហករណ៍។ អ្នកស្រី បានរៀបរាប់ឡើងវិញអំពីការស្លាប់របស់ប្តីរបស់អ្នកស្រី ដោយសារតែមានបញ្ហាបេះដូងនៅក្នុងឆ្នាំ១៩៩៥។ អ្នកស្រីជឿជាក់ថា រឿងនេះកើតចេញពីការងារធ្ងន់ធ្ងរ ដែលគាត់ត្រូវបានតម្រូវឱ្យធ្វើក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រី ក៏បានរៀបរាប់ពីការលំបាក ដែលគាត់បានស៊ូទ្រាំរស់នៅជាស្ត្រីមេម៉ាយ និងជាអ្នករស់រានមានជីវិតតែមួយគត់នៅក្នុងគ្រួសាររបស់គាត់។ អ្នកស្រី បានប្រាប់តុលាការថា គាត់បានបាត់បង់សមាជិកគ្រួសារសរុបចំនួន ២២នាក់ និងសាច់ញាតិដោយសារជំងឺ គ្រាប់មីន និងការសម្លាប់។ ការជំរុញឱ្យមានចូលរួមនៅក្នុងដំណើរការនីតិវិធីជាដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីស្វែងរកយុត្តិធម៌ ហើយអ្នកស្រីបានជំរុញឱ្យសហព្រះរាជអាជ្ញាធានាឱ្យចេញសាលក្រមមុនពេលដែលសហជនជាប់ចោទបានស្លាប់។ អ្នកស្រីបាននិយាយថា "ចារីគួរតែត្រូវ បានដាក់ទណ្ឌកម្មរយៈពេល ១០០០ឆ្នាំ ឬអស់មួយជីវិតរបស់ពួកគេ ហើយពួកគេមិនគួរត្រូវបានកើតជាមនុស្សទៀតទេ"។ សាក្សី

បានស្នើថា ទ្រព្យរបស់សហជនជាប់ចោទទាំងក្នុង និងក្រៅប្រទេសកម្ពុជា គួរត្រូវបានរឹបអូសដើម្បីទូទាត់សង ជនរងគ្រោះនៅក្នុងករណីដែលសាលក្រមរកឃើញថា មានពិរុទ្ធភាពត្រូវបានសម្រេច។

### ឆ.៥. ការសួរសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី សួរទៅកាន់សហជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណី បានសួរបីសំណួរដល់សហជនជាប់ចោទ។ សំណួរដំបូងបានសួរថា តើគោលនយោបាយ ដែលបានកើតឡើងនាំឱ្យមានការកាត់ទោស និងការសម្លាប់ម្តាយ និងប្អូនប្រុសរបស់គាត់ចំពោះការខកខាន មិនប្រគល់មាសរបស់ខ្លួនឱ្យទៅសហករណ៍ មានកើតឡើងដែរឬទេ? សំណួរទីពីរ អ្នកស្រីបានថ្កោលទោសសហជនជាប់ចោទ និងសួរថា "តើអ្នកធ្លាប់ស្រម៉ៃពីស្ថានភាពរបស់ប្រជាជនកម្ពុជា ដែលបានយំនៅក្នុងថ្លុកឈាម ហើយបានសួរពីលក្ខណៈកំហុសអ្វីដែលពួកគេបានធ្វើខុស ហេតុអ្វីបានជាពួកគេត្រូវបានសម្លាប់ និងត្រូវការមានយុត្តិធម៌? តើអ្នកធ្លាប់ដែលស្រម៉ៃទេ? សំណួរទីបី បានសំដៅដល់សេចក្តីថ្លែងការណ៍ធ្វើឡើងដោយសហជនជាប់ចោទបដិសេធការដឹងការសម្លាប់រង្គាល ដើមបណ្តឹងរដ្ឋប្បវេណីបានសួរថា "[ តើ] អ្នកចេះខ្មាស់គេដែរឬទេ.... ថាអ្នកជាមេដឹកនាំជាន់ខ្ពស់ ហើយអ្នកមិនដឹងអ្វីសោះ?"

លោក **នួន ជា** បានបដិសេធមិនឆ្លើយសំណួរ ដោយលើកឡើងពីការអស់កម្លាំងខ្លាំង និងការឈឺក្បាល។ លោក **ខៀវ សំផន** បានឆ្លើយតបថា គាត់មិនមែនជាមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ប៉ុន្តែ គ្រាន់តែប្រមុខរដ្ឋដោយគ្មានសិទ្ធិអំណាចប្រតិបត្តិ គឺដូចជាអ្នកកាន់តំណែងមុនគឺ **សម្តេចសីហនុ**។ បើទោះបីជាមានការចោទប្រកាន់ថា គណៈមជ្ឈិមជាអង្គការកំពូលរបស់បក្សកុម្មុយនីស្ត លោក **ខៀវ សំផន** បានអះអាងថា នៅក្នុងការអនុវត្តតួនាទីរបស់គាត់នៅក្នុងបក្សកុម្មុយនីស្ត ត្រូវបានកម្រិតឱ្យចែកចាយទំនិញដោយអនុលោមតាមសេចក្តីណែនាំ ដែលគាត់បានទទួលបានពីគណៈកម្មាធិការអចិន្ត្រៃយ៍។ គាត់ក៏បានលើកឡើងម្តងទៀតពីសេចក្តីថ្លែងការណ៍ធ្វើឡើងតាំងពីដើមដោយលោក **នួន ជា** ថា ការអប់រំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានចេតនាលាងសម្អាតធាតុបុគ្គលជាថ្មី មិនមែនកម្ទេចបុគ្គលនោះទេ។ គាត់បានបដិសេធការដឹងអំពីគោលនយោបាយរឹបអូសទ្រព្យសម្បត្តិឯកជនណាមួយជាជាងដីធ្លី ដែលគាត់បានបញ្ជាក់គឺតម្រូវសម្រាប់ធ្វើការអភិវឌ្ឍន៍កសិកម្ម។

### ឆ.៦. ឥរិយាបថរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន

ដើមបណ្តឹងរដ្ឋប្បវេណី មានអារម្មណ៍មិនសប្បាយចិត្ត នៅពេលដែលគាត់កំពុងតែផ្តល់សក្ខីកម្ម។ អ្នកស្រីបាននិយាយយ៉ាងឆាប់រហ័ស ហើយនៅពេលខ្លះ បញ្ហានេះប៉ះពាល់ដល់ភាពច្បាស់លាស់នៃសក្ខីកម្មរបស់គាត់។ ដោយសារតែភាគី មិនបានចោទសួរសំណួរដល់សាក្សី នោះគឺគ្មានឱកាសដើម្បីបញ្ជាក់ពីផ្នែកណាមួយនៃសក្ខីកម្មរបស់អ្នកស្រីថា មិនទាន់ច្បាស់នោះទេ។

### ជ. សក្ខីកម្មរបស់អ្នកស្រី ឆេង អេងលី (TCCP-13)

វគ្គសវនាការចុងក្រោយនៅថ្ងៃពុធ គឺលោកស្រី **ឆេង អេងលី** ដើមបណ្តឹងរដ្ឋប្បវេណី អាយុ ៦០ឆ្នាំរូបនេះ បានផ្តល់សក្ខីកម្មនៅមុខតុលាការតាមរយៈមធ្យោបាយសោតទស្សន៍ពីប្រទេសបារាំង។[12] សាក្សីបច្ចុប្បន្នរស់នៅក្នុងទីក្រុងប៉ារីស បានរៀបរាប់ឡើងវិញអំពីបទពិសោធន៍របស់អ្នកស្រី អំឡុងពេលការជម្លៀស

ប្រជាជនចេញពីទីក្រុងភ្នំពេញ និងបទពិសោធន៍របស់គាត់រស់នៅក្នុងសហករណ៍អំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រីបានចាំថា បានឃើញនូវឧប្បត្តិហេតុដ៏កាចសាហាវជាច្រើននៅក្នុងអំឡុងពេលនោះ។ សាក្សីបានប្រាប់តុលាការថា អ្នកស្រី ធ្លាប់ប៉ងធ្វើអត្តឃាតខ្លួនឯងដែរ ដោយសារធ្វើការងារអស់កម្លាំង និងមានអាហារមិនគ្រប់គ្រាន់។

### *៨.១. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

អ្នកស្រី **ឆេង អេងលី** បានប្រាប់តុលាការ ពីការដែលអ្នកស្រីត្រូវបានគេបង្ខំឱ្យចាកចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាមួយម្តាយចាស់ជរា និងបងប្អូនប្រុសពីរនាក់របស់អ្នកស្រី។ អ្នកស្រីបានចាំថា ខ្មែរក្រហមបានប្រាប់គ្រួសាររបស់គាត់ឱ្យចាកចេញពីផ្ទះរបស់ពួកគេ ដោយសារតែការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកអាចនឹងបំផ្លាញទីក្រុង និងផ្ទះរបស់អ្នកស្រី។ អ្នកស្រី បានចាកចេញតាមផ្លូវជាតិលេខ១ ឆ្ពោះទៅកាន់កៀនស្វាយ។ ចំពោះការធ្វើដំណើរ អ្នកស្រីបានឃើញទារកដែលគេបោះបង់ចោលនៅលើចិញ្ចើមផ្លូវ ប៉ុន្តែ នៅពេលដែលអ្នកស្រីបានព្យាយាមជួយសង្គ្រោះ ទាហានខ្មែរក្រហមមិនអនុញ្ញាតឱ្យនាងជួយ ហើយ "ចាប់ហែកទារកដាច់ចេញពីគ្នា" នៅនឹងមុខរបស់អ្នកស្រី។ អ្នកស្រី ក៏បានប្រទះសាកសពជាច្រើននាក់ដែលបានស្លាប់នៅតាមផ្លូវ។ រូបិយប័ណ្ណនៅមានសុពលភាពរយៈពេលពីរ ឬ បីសប្តាហ៍បន្ទាប់ពីថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ ដូច្នេះហើយ សាក្សី និងក្រុមគ្រួសារ នៅតែអាចទិញអាហារដើម្បីបរិភោគក្នុងអំឡុងពេលការធ្វើដំណើររបស់ពួកគេ។ នៅពេលដែលពួកគេបានទៅដល់កៀនស្វាយហើយ ទាហានឈុតខ្មៅបានបង្ខំឱ្យពួកគេបន្តទៅមុខទៀតរហូតទៅដល់ រកាកោង ខេត្តបាត់ដំបង ដែលជាកន្លែងពួកគេត្រូវបានដាក់ឱ្យនៅក្នុងសហករណ៍។

### *៨.២. បទពិសោធន៍ការងារនៅក្នុងសហករណ៍ខេត្តបាត់ដំបង*

អ្នកស្រី បានប្រាប់តុលាការថា ខ្មែរក្រហមបានប្រកាសប្រាប់ពួកគេអំឡុងពេលការធ្វើដំណើររបស់ពួកគេទៅកាន់រកាកោងថា "ប្រជាជនថ្មី" នឹងត្រូវបានបង្ខំឱ្យចូលទៅក្នុងសហករណ៍ នៅពេលដែលពួកគេបានមកដល់។ បន្ទាប់ពីធ្វើដំណើរមកដល់រកាកោង រាល់ទ្រព្យសម្បត្តិ ឬអីវ៉ាន់របស់ពួកគេទាំងអស់ ត្រូវបានគេរឹបអូសសម្រាប់ការប្រើប្រាស់រួម។ សាក្សី បានកាត់ស្មានថា រឿងនេះត្រូវបានធ្វើឡើងដើម្បីបង្កើតស្ថានភាពនៃភាពស្មើគ្នា ដែលគ្មាននរណាម្នាក់មានជាងនរណាមួយផ្សេងឡើយ។ នៅក្នុងសហករណ៍ ប្រជាជនត្រូវបានគេចាត់ថ្នាក់ជាបីផ្នែកៈ ថ្នាក់ក្មេង ថ្នាក់វ័យជំទង់ និងថ្នាក់មនុស្សចាស់។ ក្រុមនីមួយៗ មានសមាជិកប្រមាណ ២០នាក់ និងប្រធានអង្គភាពមួយ ដែលបានចាត់តាំងក្នុងក្រុមនេះ។ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបញ្ជូនទៅថ្នាក់វ័យជំទង់ ដែលអ្នកស្រីបានអះអាងថា ប្រធានអង្គភាពជាមនុស្សឃោរឃៅ និងគឃ្លើន។

អ្នកស្រី **ឆេង អេងលី** បានរៀបរាប់អំពីបទពិសោធន៍រស់នៅក្នុងសហករណ៍។ អ្នកស្រីបានប្រាប់តុលាការថា អ្នកស្រីត្រូវបានគេដកហូតសិទ្ធិសេរីភាព មិនមានអាហារគ្រប់គ្រាន់ និងត្រូវបានប្រព្រឹត្តយ៉ាងអាក្រក់មកលើខ្លួនអ្នកស្រីនៅក្នុងសហករណ៍នេះ។ សាក្សី បានរៀបរាប់ថា គាត់ត្រូវបានគេហាមឃាត់មិនឱ្យញញឹម ឬយំ។ អ្នកស្រីបានរម្លឹកថា គាត់ទទួលបានតែបបររាវបីវែកដើម្បីបរិភោគនៅពេលព្រឹក និងពេលល្ងាច។ ទាក់ទងនឹងការព្យាបាល គឺមានតែថ្នាំគ្រាប់អាចម៍ទន្សាយទេ ដែលអាចរកបានសម្រាប់ពេលឈឺ។ នៅចំណុច

មួយ សាក្សីបានចាំថា គាត់បានសន្លប់ដោយសារតែអស់កម្លាំងពេក ប៉ុន្តែ បានដឹងខ្លួនឡើងវិញនៅមុនពេលដែលនរណាម្នាក់បានប៉ុនប៉ងចាក់សារធាតុរាវលើរូបអ្នកស្រី។

ដោយលើកឡើងពីបញ្ហាទណ្ឌកម្មនៅក្នុងសហករណ៍ អ្នកស្រី **ឆេង អេងលី** បានចាំថា នៅថ្ងៃទីពីរបន្ទាប់ពីអ្នកស្រីបានមកដល់ មនុស្សប្រមាណ ២០នាក់ (រួមទាំងប្អូនគ្រួសារ និងក្មេងប្រុសម្នាក់) បានធ្វើការប្រឆាំងតវ៉ាសុំត្រឡប់ទៅភ្នំពេញវិញ។ ខ្មែរក្រហមពីដំបូងបានគំរាមសម្លាប់ក្រុមអ្នកតវ៉ា បន្ទាប់មកបានចាប់ចងដៃរបស់ពួកគេរួមគ្នា និងចងស្លាបសេកបង្ខំឱ្យចាកចេញ។ សាក្សី បានប្រាប់តុលាការដោយសន្និដ្ឋានថាក្រុមនេះត្រូវបានសម្លាប់ បន្ទាប់ពីពួកគេទាំងអស់គ្នាបាត់ខ្លួន។ សាក្សី ក៏បានរម្លឹកឡើងវិញអំពីជោគវាសនាមិត្តភក្តិរបស់គាត់ឈ្មោះ **មុយ** អ្នកភៀសខ្លួនមកពីភ្នំពេញដែរ ដែលបានប្រាប់ពីអាថ៌កំបាំងទៅកាន់អ្នកស្រីថាគាត់មានការព្រួយបារម្ភអំពីបងប្អូនបង្កើតរបស់គាត់។ នៅថ្ងៃបន្ទាប់ ទាហានខ្មែរក្រហមបានហៅអ្នកទាំងពីរ **មុយ** និងដើមបណ្តឹងរដ្ឋប្បវេណី ហើយបានបញ្ជាឱ្យពួកគេឆ្លងកាត់វាលស្រូវ។ បន្ទាប់មក **មុយ** ត្រូវបានគេបញ្ជាឱ្យជីករណ្តៅមួយ និងបន្ទាប់ពីជីករណ្តៅហើយ ពួកទាហានបានរុញគាត់ចូលទៅក្នុងរណ្តៅ ហើយកប់ទាំងរស់តែម្តង។ អ្នកស្រី **ឆេង អេងលី** ក្រោយមកបានឮ ទាហាន និយាយថា «ឥឡូវនេះ យើងបានបញ្ជូនអ្នកទៅជួបជាមួយគ្រួសាររបស់អ្នកហើយ។» បន្ទាប់ពីមើលឃើញមិត្តភក្តិរបស់អ្នកស្រីស្លាប់ ដើមបណ្តឹងរដ្ឋប្បវេណី ក្រោយមកទៀតត្រូវបានគេ បញ្ជាដោយទាហានឱ្យត្រឡប់មកផ្ទះវិញ និង «ធ្វើការធ្ងន់ធ្ងរ»។ អ្នកស្រីប្រាប់តុលាការថា គាត់ភ័យខ្លាចពេកមិនហ៊ានប្រាប់នរណាម្នាក់អំពីហេតុការណ៍នោះទេ។

### *ជ.៣. ទុក្ខវេទនា និងព្យសនកម្ម បណ្តាលមកពីបទឧក្រិដ្ឋក្នុងករណី ០០២*

អ្នកស្រី **ឆេង អេងលី** បានប្រាប់អង្គជំនុំជម្រះថា គាត់ត្រូវបានទទួលរងទុក្ខទាំងផ្នែកផ្លូវចិត្ត និងផ្លូវកាយ។ អ្នកស្រីបានលើកឡើងថា ការធ្វើពលកម្មធ្ងន់ធ្ងរ និងកង្វះអាហាររូបត្ថម្ភ បានធ្វើឱ្យអ្នកស្រីគ្មានការលូតលាស់។ អ្នកស្រី ក៏បានប្រាប់តុលាការទៀតថា គាត់បានសញ្ជឹងគិតធ្វើអត្តឃាតនៅពេលណាមួយ ហើយមិនអាចទ្រាំមើល ឬ ឮសំឡេងខ្លាំងៗដោយសារការជួបប្រទះរបស់អ្នកស្រី។

### *ជ.៤. ឥរិយាបថរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន*

សក្ខីកម្មរបស់អ្នកស្រី **ឆេង អេងលី** ត្រូវបានរំខានដោយសារតែបញ្ហាបច្ចេកទេស (សូមមើលផ្នែកទី៤ គ) ប៉ុន្តែ អ្នកស្រី នៅតែរក្សាភាពអត់ធ្មត់ និងបន្តផ្តល់សក្ខីកម្មយឺតៗ និងច្បាស់ៗ។ មានពេលខ្លះឃើញថាដើមបបណ្តឹងរដ្ឋប្បវេណីរូបនេះ មានការរំជើបរំជួលអារម្មណ៍ខ្លាំង ដូចនេះឃើញថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាជាតិ បានជួយតាំងសំណួរសួរដល់អ្នកស្រី ឲ្យបកស្រាយឲ្យបានច្បាស់ នូវអ្វីដែលអ្នកស្រីបានជួបប្រទះ។

## ឈ. សក្ខីកម្មរបស់លោក នូរ ហ៊ាន់ (TCP-100)

ដើមបណ្តឹងរដ្ឋប្បវេណីលោក **នូរ ហ៊ាន់** អាយុ ៧៩ ឆ្នាំ បានធ្វើដំណើរពីផ្ទះសព្វថ្ងៃរបស់គាត់នៅក្នុងរដ្ឋតិចសាស សហរដ្ឋអាមេរិក ក្នុងគោលបំណងមកផ្តល់នូវសេចក្តីថ្លែងពីព្យសនកម្ម និងការរងទុក្ខសោករបស់គាត់។ គាត់កើតនៅខេត្តព្រៃវែង ហើយបាននិយាយអំពីការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ។[13]

## *ឈ.១. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

នៅអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ លោក **នូរ ហ៊ាន់** បានរម្លឹកឡើងថា ប្រជាជនជាច្រើនកំពុងចាកចេញពីទីក្រុងនៅកណ្តាលថ្ងៃនារដូវប្រាំង។ លោក **នូរ ហ៊ាន់** បានរៀបរាប់ថា ទាហានខ្មែរក្រហម ដែលគាត់បានឃើញនៅពេលនោះ បានកាន់កាំភ្លើងអាកា ៤៧ និងស្លៀកពាក់ឯកសណ្ឋានពណ៌ខ្មៅជាមួយនឹងមួកកន្ទឹប និងស្បែកជើងកង់ឡាន។ ដោយរៀបរាប់អំពីស្ថានភាព "វឹកវរ" សាក្សីបានប្រាប់តុលាការថា ប្រជាជនមិនត្រូវបានអនុញ្ញាតឱ្យយកអីវ៉ាន់ជាច្រើននោះទេ ហើយលោកបានចាំថា បានឃើញមនុស្សមួយចំនួនដើរដោយគ្មានសម្លៀកបំពាក់ ឬស្បែកជើង ឬប្រើដើមចេកធ្វើជាស្បែកជើង។ លោក **នូរ ហ៊ាន់** បានបន្ថែមថា គ្មានអាហារអាចរកបាននោះទេ ហើយអនាម័យ គឺពិតជាមានភាពកខ្វក់ខ្លាំងណាស់។ លោកបានរម្លឹកពីសត្វរុយដូចជា "ហ្វូងឃ្មុំ" មករោមជុំវិញលាមកមនុស្សនៅគ្រប់ទីកន្លែងដោយសារតែខ្វះបង្គន់អនាម័យ។ សាក្សីបានប្រាប់តុលាការថា ប្រជាជនត្រូវបានបង្ខំឱ្យរក្សាការផ្លាស់ទី ហើយជាលទ្ធផល មនុស្សឈឺត្រូវបានទុកចោល ហើយគាត់បានឃើញមនុស្សម្នាបានដេកស្លាប់នៅតាមផ្លូវ។

លោក **នូរ ហ៊ាន់** និងក្រុមគ្រួសាររបស់គាត់ បានធ្វើដំណើរចេញពីភ្នំពេញតាមផ្លូវជាតិលេខ១ ឆ្ពោះទៅកាន់ខេត្តព្រៃវែង និងស្វាយរៀង។ មួយខែបានកន្លងផុតទៅមុនពេលដែលក្រុមគ្រួសារគាត់ បានទៅដល់ខេត្តព្រៃវែង។ នៅអំឡុងពេលធ្វើដំណើរ សាក្សីបានផ្តល់សក្ខីកម្មថា ការខ្វះស្បៀងអាហារ និងថ្នាំពេទ្យ គឺជាបញ្ហាប្រឈមដ៏ធំបំផុត។ ទោះជាយ៉ាងណាក៏ដោយ លោកបានចាំថា មានទាហានពីរនាក់បានផ្តល់ស្បៀងដល់គ្រួសាររបស់គាត់ ខណៈដែលពួកគេ ព្យាយាមឆ្លងសាឡាងនៅក្នុងការធ្វើដំណើររបស់ពួកគេ។ នៅពេលដែលគ្រួសាររបស់គាត់បានទៅដល់វត្តចម្ប៉ា គាត់បានឃើញសេចក្តីប្រកាសសរសេរនៅលើក្តារខៀន អំពាវនាវទៅកាន់អតីតមន្ត្រីរាជការសាធារណៈ និងប៉ូលីសក្នុងរបប **លន់ នល់** មកចុះឈ្មោះរបស់ពួកគេ និងវិលត្រឡប់ទៅកាន់ភ្នំពេញវិញ ដើម្បីជួយរៀបចំទីក្រុងឡើងវិញ។ លោក **នូរ ហ៊ាន់** មិនបានជឿសេចក្តីប្រកាសនេះទេ ហើយបានគិតថា វាជារឿងមិនប្រក្រតី ដែលពួកអតីតទាហាន ត្រូវបានគេបំបែកចេញពីមនុស្សផ្សេងទៀត។ សាក្សីបានប្រាប់តុលាការថា គាត់មានអារម្មណ៍គ្រោះថ្នាក់ ហើយបានសុំឱ្យកូនរបស់គាត់ឈប់ហៅគាត់ថា "ប៉ាប៉ា" និងប្រពន្ធរបស់គាត់ថា "ម៉ាម៉ា"។ នៅពេលមកដល់ខេត្តព្រៃវែង លោក **នូរ ហ៊ាន់** បានប្រាប់តុលាការថា ខ្មែរក្រហមបានពិនិត្យមើលសម្ភារផ្ទាល់ខ្លួនរបស់ពួកគាត់ និងបានបង្ខំឱ្យពួកគាត់ចុះឈ្មោះ។ សាក្សីបាននិយាយថា គ្រួសាររបស់គាត់ បានស្នាក់នៅទីនោះតែមួយសប្តាហ៍ទេ មុនពេលពួកគេត្រូវបានបញ្ជូនទៅកាន់ភូមិមួយទៀតចំងាយ ៣គីឡូម៉ែត្រ។

## *ឈ.២. មតិយោបល់ទៅលើបុគ្គលិកលក្ខណៈរបស់លោក ខៀវ សំផន*

លោក **នូរ ហ៊ាន់** បានផ្តល់សក្ខីកម្មថា លោកបានទទួលព័ត៌មានពីសមាជិកគ្រួសារដែលបានធ្វើការនៅក្នុងសាលាខេត្តព្រៃវែងថា លោក **ខៀវ សំផន** នឹងវិលត្រឡប់ទៅកាន់ភ្នំពេញដើម្បីរៀបចំប្រទេស។ នៅពេលដែលបានចុចសួរដោយសហមេធាវីអន្តរជាតិលោក **ខៀវ សំផន** លោក **អាកទួរ វែកគែន (Mr. Arthur Vercken)** សាក្សីបានប្រាប់តុលាការថាលោក **ខៀវ សំផន** ល្បីល្បាញពី "ភាពស្អាតស្អំ" "មិនពុករលួយ" និងមាន "ជំហរទន់ភ្លន់។" គាត់បានសំដៅទៅលើពាក្យចចាមអារាំមដែលគាត់បានឮថា លោក **ខៀវ សំផន** បានបដិសេធមិនទទួលយករថយន្តម៉ែកសឺខេសថ្មី ដែលបានទុកចោលនៅក្រោមផ្ទះរបស់លោកដើម្បីសូក

ប៉ាន់គាត់។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីសេចក្តីអត្ថាធិប្បាយ សាក្សីបានបន្តចាត់ទុកលោក **ខៀវ សំផន** ថាជា "ត្រីក្នុងត្រក ជាមួយនឹងត្រីស្អុយ" ដោយពន្យល់ថា លោក **ខៀវ សំផន** មិនអាចអះអាងថា ជាមនុស្សម្នាក់ដែលស្អាតស្អំនោះទេ បន្ទាប់ពីលោកបានទៅរស់នៅជាមួយ "ក្រុមខ្មែរក្រហម ដែលមានបេះដូងពណ៌ខ្មៅ"។

## *ឈ.៣. ទុក្ខវេទនា និងព្យសនកម្ម ដោយសារបទឧក្រិដ្ឋក្នុងករណី ០០២*

លោក **នូវ ហ៊ាន់** បានរៀបរាប់ពីការបាត់បង់កូនស្រី និងក្រុមគ្រួសាររបស់ប្អូនប្រុសថ្លៃទាំងមូល បានស្លាប់ក្នុងរបបខ្មែរក្រហម។ បន្ទាប់ពី រូបថតសខ្មៅរបស់កូនស្រីគាត់ត្រូវបានបង្ហាញនៅលើអេក្រង់ សាក្សីបានប្រាប់តុលាការអំពីអារម្មណ៍សោកសៅ ទុក្ខព្រួយ និងការសោកស្តាយរបស់គាត់ បើទោះបីជាការខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការសម្រួលអារម្មណ៍ខឹងរបស់គាត់។ លោកបានលើកឡើងថា លោកមិនបានសុំសំណងជួសជុលជាថវិកានោះទេ ប៉ុន្តែ ចង់បានតែឱកាសដើម្បីសំដែងការរងទុក្ខវេទនារបស់គាត់។ លោកបានអំពាវនាវដល់តុលាការឱ្យផ្តល់យុត្តិធម៌ និងអនុញ្ញាតឱ្យជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេទទួលបាន "សន្តិភាព"។ ដើមបណ្តឹងរដ្ឋប្បវេណីបានថ្កោលទោស ខ្មែរក្រហមទៅលើការអនុវត្តន៍គោលការណ៍ "ម្នាក់ៗមានមួកពាក់ ចង់ឱ្យម្នាក់ៗមានស្បែកជើងមួយគូពាក់ ប៉ុន្តែ សម្ភារទាំងពីរនេះ មានទំហំតែមួយទេ ហើយទំហំតូច យកទៅប្រគល់ឱ្យអ្នកដែលទទួលក្បាលធំជើងធំដើម្បីទទួលមួក និងរបស់អង្គការឱ្យយកទៅពាក់លើក្បាលបានទាល់តែចាំងក្បាលរបស់ខ្លួនសិន បានពាក់មួកនោះត្រូវ ព្រោះមួកវាតូចនៅក្នុងគោលនយោបាយ។ លោក **នូវ ហ៊ាន់** បានរិះគន់ទៅលើគោលនយោបាយ "អង្គការ មហាលោតផ្លោះ" ដែលដាក់ឡើងដោយខ្មែរក្រហម។ លោកបានពន្យល់ថា វាជារឿងដែល "មិនអាចទៅរួចទេ" ដើម្បីអភិវឌ្ឍប្រទេសមួយ ខណៈដែលពួកគេបានបង្ខំមនុស្សឱ្យធ្វើការ និងបានសម្លាប់បញ្ញវន្តដែលជា "សសរទ្រូងនៃប្រទេសជាតិ"។ នៅទីបញ្ចប់លោកបានសម្តែងនូវ "ការសោកស្តាយ" ចំពោះលោក **ខៀវ សំផន** ថា ត្រីមួយក្នុងកន្ត្រង ហើយធម្មតាខ្មែរយើង គឺថាត្រីមួយកន្ត្រងស្អុយតែមួយ ស្អុយទាំងអស់ ហើយគាត់បានអំពាវនាវដល់តុលាការឱ្យស្វែងរកយុត្តិធម៌ឱ្យបានសម្រាប់អ្នកទាំងអស់គ្នា រួមទាំងមេដឹកនាំខ្មែរក្រហម។

## *ឈ.៤. សំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី សួរទៅកាន់សហជនជាប់ចោទ*

ដើមបណ្តឹងរដ្ឋប្បវេណី បានសួរសំណួរពីរទៅកាន់សហជនជាប់ចោទ។ ជាដំបូង គាត់បានសួរដោយសំដៅទៅលើ សេចក្តីថ្លែងការណ៍មុនហ្នឹង ដែលសហជនជាប់ចោទបានបដិសេធថា មិនដឹងពីបទឧក្រិដ្ឋ លោក **នូវ ហ៊ាន់** បានសួរថា តើពួកគេអាចបដិសេធថា មិនដឹងថាយ៉ាងដូចម្តេច នៅពេលដែលមេដឹកនាំកម្ពុជាប្រជាធិបតេយ្យត្រូវបានគេសម្លាប់ ហើយបាត់ខ្លួនខណៈដែលខ្លួនស្ថិតនៅក្នុងអំណាច? សំណួរទីពីនោះ ដើមបណ្តឹងបានសួរថា តើហេតុផល និងចេតនាអ្វី ដែលនៅពីក្រោយការអភិវឌ្ឍប្រទេសជាតិ នៅពេលដែលបញ្ញវន្តត្រូវបានកោះហៅពីបរទេស ដើម្បីយកមកសម្លាប់?

មុនពេលឆ្លើយតបទៅនឹងសំណួរដែលបានសួរ លោក **ខៀវ សំផន** បានសម្តែងនូវការសោកស្តាយចំពោះការបាត់បង់ក្រុមគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ចំពោះសំណួរទីមួយលោក **ខៀវ សំផន** បាននិយាយថា លោក "ជាមេដឹកនាំគ្មានប្រសិទ្ធភាព" ហើយត្រឹមតែត្រូវបានគេ បង្ហាញនូវ "រឿងល្អៗ" ប៉ុន្តែមិនមែនជា "អំពើយង់ឃ្នង" ដែលបានប្រព្រឹត្តក្នុងអំឡុងរបបនោះទេ។ សម្រាប់សំណួរទីពីរ លោក **ខៀវ សំផន**

បានលើកឡើងថា គាត់បានចូលរួមជាមួយខ្មែរក្រហម "ដោយចៃដន្យ" ដែលបំណងរបស់គាត់ គឺដើម្បីបង្រួបបង្រួមកម្លាំងជាតិ ដើម្បីរំដោះប្រទេស មិនមែនដើម្បីសម្លាប់ប្រជាជនកម្ពុជាស្លូតត្រង់នោះទេ។

លោក **នួន ជា** ដែលសន្តិសុខពីរនាក់បានជួយឱ្យក្រោកឈរនៅក្នុងបន្ទប់ឃុំឃាំង បានអះអាងថា "នៅក្នុងអំណាចប្រតិបត្តិ ខ្ញុំមិនមានអំណាចអ្វីទាំងអស់"។ ដោយនិយាយលម្អិតពីតួនាទី និងការទទួលខុសរបស់គាត់ក្នុងរបបខ្មែរក្រហម លោកបានលើកឡើងថា:

> មិនមែនខ្ញុំគេចវេះពីការទទួលខុសត្រូវទេ។ ខ្ញុំសូមបញ្ជាក់ម្តងទៀត ថាការខូចខាត ការគ្រោះថ្នាក់របស់ជាតិខ្ញុំ ក្នុងឋានៈខ្ញុំ ជាអ្នកទទួលនាទីដឹកនាំ ខ្ញុំត្រូវតែទទួលការខុសត្រូវ។ ខ្ញុំសូមទទួលដោយស្មោះអស់ពីដួងចិត្ត។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

លោក **នួន ជា** បានបញ្ចប់ការឆ្លើយតបរបស់គាត់ដោយសម្តែងនូវការចូលរួមមរណទុក្ខ ចំពោះការបាត់បង់សមាជិកក្រុមគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី។

### *ឈ.៥. ឥរិយាបថរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន*

លោក **នូវ ហ៊ន់** បានបង្ហាញខ្លួនដោយមិនច្រឡោត និងបានផ្តល់សក្ខីកម្មយ៉ាងស្ងៀមស្ងាត់។ បើទោះបីជា ការចងចាំពីពេលវេលានៃព្រឹត្តិការណ៍របស់គាត់ នៅពេលខ្លះមិនស៊ីចង្វាក់ក៏ដោយ។ ដើមបណ្តឹងរដ្ឋប្បវេណី មានភាពប្រាកដប្រជា និងភាពច្បាស់លាស់ នៅពេលដែលគាត់បានចោទសំណួរសួរ និងផ្តល់យោបល់ទៅលើសេចក្តីថ្លែងការណ៍របស់គាត់។

## ញ. **សក្ខីកម្មរបស់អ្នកស្រី សូផាន់ សុវណ្ណី** (TCCP-149)

ដើមបណ្តឹងរដ្ឋប្បវេណី **សូផាន់ សុវណ្ណី** អាយុ ៥៧ឆ្នាំ គឺជាអ្នកបន្ទាប់ ដែលផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការទាក់ទងទៅនឹងព្យសនកម្ម និងការរងទុក្ខវេទនា ដែលអ្នកស្រីបានជួបប្រទះ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ សព្វថ្ងៃនេះ អ្នកស្រី គឺជាអ្នកស្រែចម្ការ ហើយកំពុងរស់នៅខេត្តពោធិ៍សាត់ ដែលមានដើមកំណើតនៅទីក្រុងភ្នំពេញ។

### *ញ.១. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

អ្នកស្រី **សូផាន់ សុវណ្ណី** បានផ្តល់សក្ខីកម្មថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អ្នកស្រីនៅក្នុងផ្ទះរបស់គាត់នៅទីក្រុងភ្នំពេញ នៅពេលដែលអ្នកស្រី បានឮការប្រកាសតាមឧបករណ៍បំពងសំឡេងចល័តមួយបញ្ជាឱ្យមនុស្សចាកចេញពីទីក្រុងភ្នំពេញ ដើម្បីជៀសវាងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក។ បើទោះបីជា ឪពុករបស់អ្នកស្រីមិនជឿថា ពួកអាមេរិកាំង ទម្លាក់គ្រាប់បែកមកលើទីក្រុងភ្នំពេញ។ សាក្សី បានប្រាប់តុលាការថា ក្រុមគ្រួសាររបស់អ្នកស្រី ត្រូវបានបង្ខំឱ្យចាកចេញ បន្ទាប់ពីទាហានខ្មែរក្រហមបានមកដល់ផ្ទះ និងបានគំរាមពួកគាត់។ នៅពេលដែលក្រុមគ្រួសាររបស់អ្នកស្រី បានមកដល់ផ្លូវធំ ក៏បានប្រទះហ្វូងមនុស្សដែលភ័យតក់ស្លុតកំពុងចាកចេញពីទីក្រុង។ អ្នកស្រី **សូផាន់ សុវណ្ណី** បានចាំថា បានឃើញមនុស្សម្នាក់ បានបដិសេធនឹងពួកខ្មែរក្រហម ហើយសុំអង្វរដើម្បីវិលត្រឡប់ទៅភ្នំពេញ។ អ្នកស្រី បានរៀបរាប់ពី

ស្ថានភាពនាពេលនោះថាជា «រឿងដែលភ្ញាក់ផ្អើល និងយល់ច្រឡំ។ អ្នកស្រីបានប្រាប់តុលាការថា អ្នកស្រីបានឃើញទាហានខ្មែរក្រហមប្រដាប់អាវុធបង្ខំប្រជាជនឱ្យចាកចេញ ឃើញសាកសពស្លាប់នៅតាមផ្លូវ និងរុយរោម ហើយនិងលាមកមនុស្សគ្រប់ទីកន្លែង។

បន្ទាប់ពីរយៈពេលពីរថ្ងៃ សាក្សី និងក្រុមគ្រួសារ បានទៅដល់ព្រែកផ្ទៅ។ នៅចំណុចមួយ សាក្សីបានចងចាំថា ទាហានខ្មែរក្រហម បានប្រកាសនៅលើឧបករណ៍បំពងសំឡេងថា ទីផ្សារ និងប្រាក់កាស លែងមានតទៅទៀតហើយ។ សាក្សី បាននិយាយថា ប្រជាជនមានការភ្ញាក់ផ្អើលជាខ្លាំង និងបានអស់សង្ឃឹមដែលឮព័ត៌មាននេះ។ មនុស្សមួយចំនួនបានបោះ និងដុតលុយរបស់ពួកគេចោលបន្ទាប់ពីបានឮដំណឹងនេះ។ អ្នកស្រី **សូផាន់ សុវណ្ណី** បានបន្តដំណើរជាមួយគ្រួសាររបស់គាត់អស់រយៈពេល ១៥ថ្ងៃ មុនពេលពួកគេបានទៅដល់ព្រែកក្ដាម ហើយបានជិះសាឡាងទៅកាន់ត្រើយម្ខាងទៀត។ អ្នកស្រីបានចាំថា ឪពុករបស់អ្នកស្រីបានសង្ឃឹមថា ក្រុមគ្រួសារអាចរត់គេចខ្លួនបានដោយឆ្លងកាត់ព្រំដែន ប៉ុន្តែ ពួកគេត្រូវបានរារាំងនៅពេលដែលយោធាខ្មែរក្រហមបានបញ្ជាឱ្យពួកគេទៅធ្វើការនៅក្នុងភូមិ។

### ៣.២. បទពិសោធន៍ការងារនៅក្នុងសហករណ៍រការកោង

បន្ទាប់ពីរយៈពេលប្រាំថ្ងៃនៅក្នុងភូមិ អ្នកស្រី **សូផាន់ សុវណ្ណី** បានចាំថា ឪពុករបស់អ្នកស្រី បានសួរប្រធានភូមិ ថាតើពួកគេអាចទៅកាន់ខេត្តកំពង់ធំ ដើម្បីស្វែងរកឪពុកម្ដាយរបស់គាត់បានដែរឬទេ? ភ្លាមៗនោះ សាក្សី និងគ្រួសារ ត្រូវបានស្ដីបន្ទោស ដោយពួកទាហានខ្មែរក្រហម និងបានចោទប្រកាន់ថាមាន “ចរិតមូលធននិយម” ពួកគេត្រូវបានប្រាប់ថា ប្រសិនបើពួកគេខិតខំធ្វើការ ឪពុកម្ដាយរបស់អ្នកស្រី អាចមកសួរសុខទុក្ខពួកគេបាន។ បន្ទាប់ពីអ្នកនេសាទត្រី បានប្រាប់គ្រួសាររបស់អ្នកស្រីថា នឹងត្រូវបានគេសម្លាប់នាពេលឆាប់ៗ ប្រសិនបើក្រុមគ្រួសាររបស់អ្នកស្រីមិនរត់គេច ក្រុមគ្រួសារអ្នកស្រីក៏បានភៀសខ្លួននៅពេលយប់នោះតាមទូកចូលទៅក្នុងព្រៃ។ ក្រុមគ្រួសាររបស់អ្នកស្រី ត្រូវបានបដិសេធ មិនឱ្យចូលទៅក្នុងភូមិទីមួយ ពីព្រោះប្រជាប្រជាន “១៧មេសា”។ គ្រួសារអ្នកស្រី ត្រូវបានទទួលយក ដោយប្រធានភូមិក្នុងសហករណ៍រកាកោង។ ដើមបណ្ដឹងរដ្ឋប្បវេណី បានប្រាប់តុលាការពីការងារលំបាក ដែលអ្នកស្រីតម្រូវឱ្យធ្វើក្នុងសហករណ៍។ អ្នកស្រីបានរម្លឹកថា ដៃរបស់អ្នកស្រី បានចេញឈាមបន្ទាប់ពីត្រូវបានបង្ខំឱ្យកាត់រុក្ខជាតិ “កក” ជារុក្ខជាតិ ដែលមានបន្លាមុតស្រួចនៅគែមៗ។ អ្នកស្រី ក៏បានរម្លឹកពីហេតុការណ៍ដែលខ្មែរក្រហមបានស្នើសុំឱ្យអ្នកស្រីប្រមូលអំបិលចំនួន ៥០គីឡូក្រាមពីភូមិមួយផ្សេងទៀត ដែលអ្នកស្រីបានជិះកង់ដឹកត្រឡប់មកវិញ។ ការធ្វើដំណើរនេះ បានចំណាយពេល ១៥ថ្ងៃ ហើយអ្នកស្រីទទួលបានអំបិលតែមួយគីឡូក្រាមជារង្វាន់តែប៉ុណ្ណោះ។

### ៣.៣. ការជម្លៀសប្រជាជនភ្លាមៗ និងបទពិសោធន៍នៅក្នុងសហករណ៍ផ្សេងៗ

អ្នកស្រី **សូផាន់ សុវណ្ណី** បានរម្លឹកថា នៅចំណុចខ្លះក្នុងអំឡុងពេលការស្នាក់នៅរបស់អ្នកស្រីនៅក្នុងសហករណ៍រកាកោង មានសេចក្ដីប្រកាសមួយថា “ប្រជាជនថ្មី” ត្រូវបានបញ្ជូនទៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលពួកគេបានសន្យាថា “សំបូរអង្ករច្រើនក្រៃលែង។” ប្រជាជនថ្មី បានគេតម្រូវឱ្យចុះឈ្មោះ និងចាកចេញតាមកាល្បតមួយ។ សាក្សីបាននិយាយថា អ្នកស្រីមានការភ្ញាក់ផ្អើលខ្លាំង នៅពេលដែលទាហានខ្មែរក្រហម បានគំរាមកំហែងបោះស្ត្រីម្នាក់ចេញពីទូក ប្រសិនបើនាងមិនអាចធ្វើឱ្យកូនកំពុងតែយំឲ្យស្ងាត់

បានទេ។ បន្ទាប់មក ក្រុមប្រជាជនថ្មីទាំងនេះ ត្រូវបានដឹកតាមរថយន្តនាំទៅកាន់ស្ថានីយរថភ្លើង ដែលពួកគេបានដាក់ចូលទៅក្នុងទូរថភ្លើងជាកន្លែងប្រើសម្រាប់ដាក់គោក្របី។ ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយថា ទូរថភ្លើងមិនបានធ្វើឱ្យអ្នករាល់គ្នាមានអារម្មណ៍ធូរស្បើយដោយខ្លួនឯងនោះទេ។ អ្នកស្រីបានរម្លឹកថា ទាហានបានឱ្យស្រ្តីបន្ទោរបង់នៅនឹងកន្លែង ដោយយកកាំភ្លើងមកគំរាម ប៉ុន្តែ ភាគច្រើនមានការភ័យខ្លាចពេក ក៏មិនហ៊ានទៅ។

នៅពេលដែលសាក្សី បានមកដល់សហករណ៍កោះពី ស្រុកកណ្តៀង អ្នកស្រីបានរម្លឹកថា ទីតាំងនៅទីនោះសុទ្ធតែព្រៃឈើតែប៉ុណ្ណោះ ហើយក្រុមគ្រួសាររបស់អ្នកស្រី តម្រូវឱ្យឆ្ការព្រៃ និងសង់ខ្ទម សម្រាប់ជ្រកដោយខ្លួនឯង។ អ្នកស្រីបានប្រាប់តុលាការថា នៅពេលនោះហើយ ដែលក្រុមគ្រួសារបានបែកបាក់គ្នា។ ឪពុករបស់អ្នកស្រី មានភារកិច្ចឆ្ការព្រៃ ហើយបងប្អូនរបស់អ្នកស្រី ត្រូវបានចាត់ឱ្យទៅអង្គភាពចល័តរបស់ភូមិ ហើយអ្នកស្រី ត្រូវបានគេចាត់ឱ្យទៅអង្គភាពចល័តស្រុក។ សាក្សីបានប្រាប់តុលាការថា អ្នកស្រីត្រូវបានបដិសេធនូវឱកាសទៅសួរសុខទុក្ខឪពុកម្តាយរបស់អ្នកស្រី ដែលមានជំងឺមុនពេលពួកគាត់បានស្លាប់។ អ្នកស្រី ក៏បានដឹងអំពីការស្លាប់បងប្អូនស្រីបីនាក់របស់អ្នកស្រីដោយសារតែជំងឺ ដែលស្លាប់ម្តងម្នាក់។ សាក្សីអាចទៅសួរសុខទុក្ខប្អូនប្រុសរបស់អ្នកស្រីបានមុនពេលដែលគាត់បានស្លាប់ និងបានរម្លឹកថា ប្អូនប្រុសរបស់គាត់បានអង្វរសុំបាយញុំាមុនពេលគាត់ស្លាប់។

ក្រោយមក សាក្សីបានលើកឡើងថា គាត់ត្រូវបានផ្ទេរទៅទីតាំងមួយផ្សេងទៀត ដើម្បីជីកប្រឡាយ និងសង់ទំនប់ទឹក ប៉ុន្តែអ្នកស្រី បានសម្រេចចិត្តដើរចូលទៅភ្នំក្រវាញជំនួសវិញ។ អ្នកស្រីបានមកដល់ដំណាក់ឈើក្រោម ដែលអ្នកស្រីបានប្រាប់ប្រធានភូមិថា គាត់បានវង្វេងផ្លូវនៅក្នុងព្រៃ។ សាក្សីបានប្រាប់តុលាការពីស្ថានភាពនៅដំណាក់ឈើក្រោមមានលក្ខណៈ "ពិបាកទ្រាំ"។ សាក្សីត្រូវបានបញ្ជាឱ្យជីកប្រឡាយ ហើយបានរម្លឹកថា ដៃរបស់អ្នកស្រីហូរឈាម និងហើម ដោយសារការលើកដី និងថ្ម។ ទោះជាយ៉ាងណាក៏ដោយ អ្នកស្រី បានលើកឡើងថា អ្នកស្រីត្រូវតែប្តេជ្ញាដើម្បី "បន្តរស់នៅ" ឱ្យបាន។

អ្នកស្រី **សុផាន់ សុវណ្ណី** បានផ្តល់សក្ខីកម្មថា អ្នកស្រីបានឃើញព្រឹត្តិការណ៍ "ដ៏រន្ធត់" នៅដំណាក់ឈើក្រោម។ អ្នកស្រីបានរម្លឹកឡើងពីស្ត្រីវ័យក្មេងម្នាក់ត្រូវបាននាំយកទៅ ហើយសម្លាប់ដោយទាហានខ្មែរក្រហម ដោយសារតែនាងត្រូវបានរកឃើញថា ព្យាយាមលាក់គ្រឿងអលង្ការ។ អ្នកស្រី ក៏បានរម្លឹកពីហេតុការណ៍ពីស្រ្តីម្នាក់ដែលត្រូវបានវាយដោយពួកទាហានខ្មែរក្រហម បន្ទាប់ពីចាប់បានដោយសារហូបដំឡូង។ បន្ទាប់ពីពួកទាហានខ្មែរក្រហម បានបង្ខំឱ្យស្រ្តីមានផ្ទៃពោះដើរដោយចងដៃមកក្រោយ ដោយត្រូវបានចោទប្រកាន់ពីការប្រព្រឹត្តកាមគុណចូលទៅក្នុងព្រៃ អ្នកស្រីបានរម្លឹកពីការឃើញទាហានជាច្រើន បានស្រាតខោអាវស្ត្រីម្នាក់ ហើយវាយរហូតដល់ស្លាប់ និងបានវះពោះរបស់នាង។ អ្នកស្រី ក៏បានរម្លឹកឡើងថា បានឃើញទាហានខ្មែរក្រហមយកកាំភ្លើងភ្ជុងស្ត្រីម្នាក់ ហើយកប់នាងនៅក្នុងរណ្តៅ ពីព្រោះ តែកជើងគ្រេចហើយ បានរារាំងមិនឱ្យនាងសម្រេចបាននូវការងារតាមចំនួនកំណត់។ សាក្សី ក៏បាននឹកឃើញដល់រថយន្តពីរគ្រឿងដឹកប្រជាជនចេញពីភូមិ។ នៅព្រឹកបន្ទាប់ រថយន្តនោះបានត្រឡប់មកវិញដោយមានតែសម្លៀកបំពាក់ និងស្បែកជើងរបស់ប្រជាជនទាំងនោះ ដែលក្រោយមក អ្នកស្រីបានសន្និដ្ឋានថា ពួកគេត្រូវបានគេសម្លាប់។

### ៣.៤. ទុក្ខវេទនា និងព្យសនកម្ម បណ្តាលមកពីបទឧក្រិដ្ឋក្នុងករណី ០០២

នៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីការរងទុក្ខវេទនារបស់អ្នកស្រី **សូផាន់ សុវណ្ណី** បានប្រាប់ថា ការឈឺចាប់ដែលអ្នកស្រី បានទទួលរងបន្ទាប់ពីការបាត់បង់ក្រុមគ្រួសារទាំងមូលគឺជារឿងមួយ "ដែលមិនអាចពិពណ៌នាបាន"។ លើសពីនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណី បាននិយាយថា ចំពោះជីវិតដែលនៅសេសសល់ គឺអ្នកស្រីមិនអាចបំភ្លេចពីការសម្លាប់ដែលអ្នកស្រីបានឃើញ នៅពេលរស់នៅក្នុងសហករណ៍នោះឡើយ។

### ៣.៥. ឥរិយាបថរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន

អ្នកស្រី **សូផាន់ សុវណ្ណី** បានផ្តល់សក្ខីកម្មដោយមានភាពត្រឹមត្រូវលម្អិត បើទោះបីជាឃើញមានទុកសោកប្រាកដមែននោះ នៅពេលរម្លឹកដល់ព្រឹត្តិការណ៍កន្លងមក។ អ្នកស្រី ត្រូវបានគេសង្កេតឃើញថា យំស្ទើរតែទាំងស្រុងនៅពេលផ្តល់សក្ខីកម្មរបស់អ្នកស្រី។ តែទោះជាយ៉ាងណាក៏ដោយ បញ្ហានេះ មិនបានប៉ះពាល់ដល់ភាពច្បាស់លាស់នៃបទពិសោធន៍ដែលអ្នកស្រីបានរៀបរាប់នោះទេ។

### ជ. សក្ខីកម្មរបស់លោក **យិន រំដួល** (TCCP-170)

ដើមបណ្តឹងរដ្ឋប្បវេណី **យិន រំដួល** អាយុ ៤៨ឆ្នាំ បានឡើងសវនាការនៅរសៀលថ្ងៃព្រហស្បតិ៍។ សាក្សី បានកើតនៅទីក្រុងភ្នំពេញ ហើយបានជម្លៀសចេញពីទីក្រុងជាមួយគ្រួសាររបស់គាត់ ដែលនៅពេលនោះគាត់មានអាយុ ១០ឆ្នាំ។ លោកបានរៀបរាប់ប្រាប់តុលាការថា គាត់បានក្លាយជាក្មេងកំព្រាក្នុងរបបខ្មែរក្រហម ហើយបានផ្តល់រឿងរ៉ាវដ៏គួរឱ្យភ័យពីបទពិសោធន៍ធ្វើការរបស់គាត់នៅអង្គភាពកុមារ និងនៅក្នុងពន្ធនាគារ។[14]

### ជ.១. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ

លោក បានផ្តល់សក្ខីភាពថា លោកមានការសប្បាយរីករាយនៅពេលដំបូង ដែលទាហានខ្មែរក្រហមបានចូលមកភ្នំពេញ។ លោកចាំបានពីការឃើញមនុស្សលើកទង់ពណ៌ស និងបានស្រែកហ៊ោនៅក្នុងទីក្រុង។ ទោះជាយ៉ាងណាក៏ដោយ ក្រោយពេលព្រឹកនោះ គាត់បានឮការបាញ់ជាច្រើនគ្រាប់នៅក្បែរសាលាស្វាយព្រៃ ហើយបានឃើញទាហានខ្មែរក្រហមបាញ់ផ្ទះដែលនៅទល់មុខផ្ទះរបស់គាត់។ ក្រោយមក បន្ទាប់ពីគ្រួសាររបស់គាត់បានចាកចេញពីផ្ទះ គាត់បានឃើញសាកសពមនុស្ស ត្រូវបានបាញ់ដោយពួកទាហាននៅតាមមហាវិថីមុនីវង្ស។ នៅព្រឹកបន្ទាប់ គាត់ និងគ្រួសារ បានទៅដល់ច្បារអំពៅ។ បន្ទាប់ពីទាហានខ្មែរក្រហមបានឆែកមើលអត្តសញ្ញាណរបស់ពួកគាត់ ហើយក៏បានបន្តដំណើរទៅកាន់ព្រែកឯង ដែលបានស្នាក់នៅរយៈពេលពីរបីថ្ងៃ។ សាក្សី បានប្រាប់តុលាការថា មិនមានអាហារគ្រប់គ្រាន់នោះទេនៅព្រែកឯង ហើយក្រុមគ្រួសាររបស់គាត់ បានសម្រេចចិត្តបន្តដំណើរទៅកាន់ភូមិកំណើតរបស់ម្តាយគាត់នៅខេត្តកណ្តាល។

ទោះជាយ៉ាងណាក៏ដោយ ពួកគេមិនអនុញ្ញាតឱ្យស្នាក់នៅក្នុងភូមិនោះទេ ដោយសារតែឪពុករបស់គាត់ធ្លាប់ជាមន្ត្រីរាជការនៅក្នុងរបប **លន់ នល់**។ ទីបំផុត គ្រួសាររបស់គាត់ បានមកដល់ឃុំមេទឹក បន្ទាប់ពីបានធ្វើដំណើរតាមខេត្តពោធិ៍សាត់ និងភ្នំពេញដោយឡាន។

### ៨.២. បទពិសោធន៍ការងារនៅក្នុងអង្គភាពកុមារ

បន្ទាប់ពីមកដល់ឃុំមេទឹក សាក្សីបានលើកឡើងថា គាត់ត្រូវបានបំបែកពីគ្រួសារជាលើកទីមួយនៅក្នុងឆាកជីវិតរបស់គាត់ ហើយត្រូវបានចាត់ឱ្យធ្វើការនៅអង្គភាពកុមារ។ នៅទីនោះគាត់បានប្រគល់ភារកិច្ចឱ្យលើកដី និងស្ទូងស្រូវ។ នៅពេលមួយនោះ គាត់បានចាំថា ដោយការស្រេកឃ្លានខ្លាំង គាត់បានលួចដំឡូងអំពៅ និងសំណាប។ ពេលទាហានខ្មែរក្រហមបានរកឃើញ គាត់ត្រូវបានគេវាយដំ និងធ្វើទារុណកម្មហើយក្រោយមកបានដាក់ក្នុងពន្ធនាគារ។

### ៨.៣. បទពិសោធន៍នៅក្នុងពន្ធនាគារ និងការគេចខ្លួនជាបន្តបន្ទាប់

ក្នុងអំឡុងពេលនៅក្នុងពន្ធនាគារ សាក្សីបានប្រាប់តុលាការពីរបៀបដែលគាត់ត្រូវគេធ្វើទារុណកម្ម និងបង្ខំឱ្យធ្វើពលកម្មធ្ងន់ធ្ងរ។ លោកក៏បានរៀបរាប់អំពីក្រុមគ្រួសារអ្នកជាប់ពន្ធនាគារ ដែលត្រូវបានកំណត់គោលដៅសម្រាប់ "កម្ទេច" ដោយបន្ថែមទៀតថា លោកធ្លាប់បានចូលកិច្ចប្រជុំម្តងដែលប្រធានភូមិ បានប្រកាសថា ប្រសិនបើនរណាម្នាក់រត់គេចខ្លួនពីពន្ធនាគារ សាច់ញាតិទាំងអស់របស់ពួកគេ នឹងត្រូវបានកម្ទេចចោល។ សាក្សីបានប្រាប់តុលាការថា ជីវិតអាក្រក់ខ្លាំងណាស់នៅក្នុងពន្ធនាគារ ដែលម្តាយរបស់គាត់បានប្រាប់គាត់ឱ្យរត់គេចខ្លួន។ នាយប់មួយ អំឡុងពេលភ្លៀងធ្លាក់ខ្លាំង គាត់បានរៀបចំគេចពីពន្ធនាគារ ធ្វើដំណើរទៅភូមិអូព្រៃក ដែលជាកន្លែងជីដូនរបស់គាត់បានរស់នៅនាពេលនោះ។[15] ក្រោយមកទៀត គាត់ក៏បានដឹងថា ម្តាយរបស់គាត់ត្រូវបានសម្លាប់ បន្ទាប់ពីការរត់គេចខ្លួនរបស់គាត់ ដោយមានភ័យខ្លាចពេក គាត់បានចាកចេញពីភូមិ ហើយក៏ចូលរួមជាមួយបងប្អូនជីដូនមួយរបស់គាត់ ដែលបម្រើការងារនៅក្នុងអង្គភាពដឹកជញ្ជូន។ ប្រធានភូមិអង្គភាព "ធើ" បានអនុញ្ញាតឱ្យគាត់ស្នាក់នៅក្នុងអង្គភាពនោះ ប៉ុន្តែបានប្រាប់គាត់ឱ្យនៅស្ងៀមអំពីការធ្វើទារុណកម្ម ការសម្លាប់ និងរំលោភ ដែលគាត់បានឃើញ។

### ៨.៤. ទុក្ខវេទនា និងព្យសនកម្ម បណ្តាលមកពីបទឧក្រិដ្ឋក្នុងករណី ០០២

ក្នុងអំឡុងរបបខ្មែរក្រហម សាក្សីជាក្មេងកំព្រា និងបានបាត់បង់សមាជិកគ្រួសារជាច្រើន។ លោកក៏បានប្រាប់តុលាការអំពីការប្រព្រឹត្តមិនត្រឹមត្រូវមកលើរូបរាងកាយ និងផ្លូវចិត្ត ដែលគាត់បានជួបប្រទះ។ លោកបន្ថែមទៀតថា ស្លាកស្នាមបណ្តាលមកពីការធ្វើទារុណកម្ម នៅតែអាចមើលឃើញនៅលើរាងកាយរបស់គាត់។ គាត់ក៏បានរៀបរាប់ពីអារម្មណ៍គិតមមៃទៅលើការធ្វើទារុណកម្ម ការចាប់រំលោភ និងការសម្លាប់ ដែលគាត់បានឃើញកាលនៅក្មេង។ លោកថ្លែងថា លោកមិនចង់បានសំណងអ្វីនោះទេ តែលោកបានស្នើសុំឱ្យសង់ចេតិយមួយសម្រាប់ឪពុកម្តាយ និងយុត្តិធម៌ជូនដល់ជនរងគ្រោះ។

### ៨.៥. សំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី សួរទៅកាន់សហជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណី បានសួរទៅសហជនជាប់ចោទថា ថាតើពួកគេបានដឹងអំពីការបាត់ខ្លួនរបស់ឪពុករបស់គាត់ គឺលោក **យិន ស៊ីដារ៉េត** ជាសាស្ត្រាចារ្យ និងជាវរសេនីយ៍ឯកនៅ**បន្ទាយដែក** ដែរឬអត់? លោកក៏បានសួរដល់សហជនជាប់ចោទទៀតថា តើពួកគេមានការពិចារណា ឬសោកស្តាយចំពោះការបំបែកបំបាក់គ្រួសារដែរឬយ៉ាងណា? ជាចុងក្រោយ សាក្សី មានអារម្មណ៍រំជើបរំជួលខ្លាំង ខណៈពេលគាត់សួរសហ

ជនជាប់ចោទថា តើពួកគេ "ហ៊ាន" ប្រាប់ពីការពិត អំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

លោក **ខៀវ សំផន** បានប្រាប់សាក្សីថា លោកគ្មានព័ត៌មានអំពីឪពុករបស់គាត់ទេ។ ហើយជនជាប់ចោទ បានពន្យល់ថា បន្ទាប់ពីគាត់បានភៀសខ្លួនចូលទៅក្នុងព្រៃ គឺគាត់ត្រូវការការពារពីខ្មែរក្រហម។ ទាក់ទងទៅនឹងការរងទុក្ខរបស់ប្រជាជន គាត់បានអះអាងថា គាត់មិនដឹងទេ ដោយលើកឡើងថា "ថ្នាក់ដឹកនាំ និងមេបញ្ជាការ បានរក្សាការសម្ងាត់នោះ។" គាត់បានបន្ថែមទៀតថា បើទោះបីជាគាត់ហាក់ដូចជាមើលពីខាងក្រៅទៅមានអំណាចខ្លះៗ ជាការពិតគាត់មិនមានអំណាច ឬក៏បានដឹងអំពីព្រឹត្តិការណ៍ដ៏ឃោរឃៅនេះទេ។

លោក **នួន ជា** ក៏បានឆ្លើយសំណួររបស់សាក្សីពីបន្ទប់ឃុំឃាំង ដែលគាត់បានប្រាប់តុលាការថា គាត់បានទទួលស្គាល់ថា ការទទួលខុសត្រូវផ្នែក "សីលធម៌" សម្រាប់អ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយបកស្រាយលម្អិតទៅលើការទទួលខុសត្រូវរបស់គាត់ ដោយនិយាយថាៈ "ខ្ញុំជាអ្នកទទួលខុសត្រូវ ទោះបីជាខ្ញុំបានប្រព្រឹត្តដោយចេតនា ឬដោយអចេតនា និងថាតើខ្ញុំបាន ឬមិនបានដឹងអំពីបទឧក្រិដ្ឋដែលបានកើតឡើងក៏ដោយ។

### *ជ.៦. ឥរិយាបថរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន*

ដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញអារម្មណ៍រំជើបរំជួលយ៉ាងខ្លាំងនៅអំឡុងពេលផ្តល់សក្ខីកម្មរបស់គាត់។ គាត់ក៏បានជម្នះនឹងការស្រក់ទឹកភ្នែក នៅពេលរម្លឹកឡើងវិញអំពីព្រឹត្តិការណ៍ដ៏ឈឺចាប់ដែលគាត់បានជួបប្រទះ។ ជាលទ្ធផល អង្គហេតុមួយចំនួនដែលគាត់បានផ្តល់ គឺមានភាពមិនច្បាស់លាស់។ ទោះជាយ៉ាងណាក៏ដោយ គាត់បានប្តេជ្ញាផ្តល់នូវសក្ខីកម្ម ដែលគាត់បាន "រង់ចាំអស់រយៈពេល ៣៤ឆ្នាំ" ហើយ។

## **ឋ. សក្ខីកម្មរបស់អ្នកស្រី ប៉ូ ឌីណា (TCCP-117)**

ដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយ ដែលបានផ្តល់សក្ខីកម្មនៅសប្តាហ៍នេះគឺ អ្នកស្រី **ប៉ូ ឌីណា** បានចូលមកផ្តល់សេចក្តីថ្លែងការណ៍ពីការរងទុក្ខវេទនានៅថ្ងៃព្រហស្បត្តិ៍នេះ។ អ្នកស្រី មានអាយុ ៦០ឆ្នាំ កើតនៅភូមិកោះដាច់ ស្រុកមុខកំពូល។ អ្នកស្រី បានប្រាប់តុលាការថា អ្នកស្រីត្រូវបានគេជម្លៀសចេញពីផ្ទះរបស់អ្នកស្រី នៅទីក្រុងភ្នំពេញ និងបានរៀបរាប់ពីបទពិសោធន៍ការងារក្នុងសហករណ៍ ហើយនិងការជាប់ពន្ធនាគារក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។[16]

### *ឋ.១. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ*

អ្នកស្រី បានប្រាប់តុលាការថា នៅពេលដែលទាហានខ្មែរក្រហមបានចូលទៅផ្ទះរបស់ពួកគេលើកដំបូងនៅក្បែរស្ថានទូតថៃ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពួកគេបានចងប្តីរបស់អ្នកស្រី ហើយធ្វើទារុណកម្មគាត់ ពីព្រោះទាហានខ្មែរក្រមទាំងនោះបានជឿថា ពួកគាត់ជាម្ចាស់ផ្ទះ។ នៅពេលល្ងាច ក្រុមទាហានខ្មែរក្រហមទីពីរ បានមកដល់ផ្ទះនោះ។ ពួកទាហានបានគំរាម និងបានប្រាប់ឱ្យចាកចេញ ពីព្រោះពួកគេត្រូវការសម្អាតទីក្រុង។ អ្នកស្រី **ប៉ូ ឌីណា** បានចាកចេញពីទីក្រុងភ្នំពេញជាមួយនឹងប្តីរបស់គាត់ ដោយចង

ចាំថា បានឃើញអតីតទាហាន **លន់ នល់** ត្រូវបានចងរឹតដៃនឹងស្លាបសេក ហើយបង្ខំឱ្យដើរទៅមុខដោយទាហានខ្មែរក្រហម។ នៅពេលដែលអ្នកស្រី បានទៅដល់ព្រែកឯង អ្នកស្រីបានឮសេចក្ដីប្រកាសដោយឧបករណ៍បំពងសំឡេង ជូនដំណឹងដល់ប្រជាជនថា អ្នកទាំងឡាយណាដែលចុះឈ្មោះ ពួកគេអាចត្រឡប់ទៅភ្នំពេញវិញ។ ប្ដីរបស់អ្នកស្រីចង់ចុះឈ្មោះ ប៉ុន្តែ អ្នកស្រី បានបញ្ឈប់គាត់មិនឱ្យចុះឈ្មោះ។ អ្នកស្រី បានបន្តដំណើររហូតទៅដល់ភូមិកំណើត គឺភូមិកោះដាច់ ខេត្តកណ្ដាល ដែលប្ដីប្រពន្ធទាំងពីរបានចុះឈ្មោះជា "ប្រជាជន១៧មេសា" ហើយបានប្រាប់ឱ្យបន្តដំណើរទៅទៀត។ បន្ទាប់ពីធ្វើដំណើររយៈពេលមួយខែ ដោយទូក និងឡាន អ្នកស្រី **ប៉ូ ឌីណា** និងស្វាមី នៅទីបំផុតបានទៅដល់ខេត្តពោធិ៍សាត់។

### ឋ.២. បទពិសោធន៍ការងារនៅក្នុងសហករណ៍ខេត្តពោធិ៍សាត់

អ្នកស្រីបានចងចាំថា នៅពេលដែលពួកគេបានទៅដល់សហករណ៍នៅក្នុងខេត្តពោធិ៍សាត់ ពួកគេបានចាត់តាំងឱ្យទៅកាន់សហករណ៍ខុសៗគ្នា។ អ្នកស្រី បានប្រាប់តុលាការអំពីប្ដីរបស់អ្នកស្រី ដែលធ្វើការនៅក្នុងវាលស្រែ ប៉ុន្តែ បានបាត់ខ្លួននៅថ្ងៃមួយ ហើយមិនឃើញត្រឡប់មកវិញទេ។ បន្ទាប់ពីរយៈពេលពីរបីខែ អ្នកស្រីបានលឮពាក្យចចាមអារ៉ាមថា គាត់ត្រូវបាននាំទៅរៀនសូត្រឡើងវិញ ពីព្រោះគាត់ត្រូវចោទប្រកាន់ថាជាវរសេនីយ៍ឯកនៅក្នុងអតីតរបប លន់ នល់។ បន្ទាប់ពីការស្លាប់របស់ស្វាមីរបស់អ្នកស្រី សាក្សីត្រូវបានបង្ខំឱ្យធ្វើការលំបាកធ្ងន់ធ្ងរនៅក្នុងសហករណ៍នេះ។ អ្នកស្រី បានយំ ហើយឈឺចាប់ ខណៈដែលអ្នកស្រីបានរម្លឹកឡើងវិញថា កូនប្រុសអាយុ ៦ឆ្នាំ បានស្លាប់នៅចំពោះមុខអ្នកស្រី ដោយសារការអត់ឃ្លាន។ អ្នកស្រីបាននិយាយថា "ខ្ញុំមានអារម្មណ៍មិនសប្បាយ និងខឹងដែលខ្ញុំមិនអាចជួយកូនប្រុសរបស់ខ្ញុំបាន... ខ្ញុំមិនមានអ្វីដើម្បីចិញ្ចឹមកូនខ្ញុំទេ។" សាក្សី បានរៀបរាប់ឡើងវិញអំពីព្រឹត្តិការណ៍មួយចំនួន ដែលអ្នកស្រីបានឃើញអំឡុងពេលអ្នកស្រីធ្វើការនៅក្នុងសហករណ៍ រួមទាំងឧប្បត្តិហេតុដែលមនុស្សត្រូវបានចាក់នឹងចំពុះទុង និងឧប្បត្តិហេតុហេតុផ្សេងថែមទៀត ដែលពួកទាហានខ្មែរក្រហមបើកការបាញ់ប្រហារទៅលើជនស៊ីវិល។ អ្នកស្រី ក៏បានចាំផងដែរថា រាងកាយត្រូវចងជាប់ជាមួយនឹងច្រវាក់ ហើយត្រូវបានវាយដំអស់រយៈពេលជាងបួនថ្ងៃ មុនពេលអ្នកស្រីបានរៀបចំគេចខ្លួន។

### ឋ.៣. បទពិសោធន៍នៅក្នុងពន្ធនាគារ

អ្នកស្រី **ប៉ូ ឌីណា** បានលើកឡើងថា អ្នកស្រីបានបដិសេធរៀបការម្ដងទៀត បន្ទាប់ពីការស្លាប់ប្ដីជាទីស្រឡាញ់របស់អ្នកស្រី។ អ្នកស្រី បានប្រាប់តុលាការថា អ្នកស្រីត្រូវបានគេវាយដំ សួរចម្លើយ ហើយនិងដាក់គុក បន្ទាប់ពីបដិសេធមិនរៀបការ។ អ្នកស្រី បានបន្ថែមទៀតថា អ្នកស្រី ត្រូវបានព្រមានថាអាចនឹង "កម្ទេចចោល" សម្រាប់ការព្រងើយកន្តើយបទបញ្ជារបស់អង្គការ។ អំឡុងពេលអ្នកស្រីជាប់នៅក្នុងពន្ធនាគារ អ្នកស្រី បានចងចាំថា បានឃើញការវាយប្រហារយ៉ាងឃោរឃៅ ដែលអ្នកទោសផ្សេងទៀតបានជួបប្រទះ រួមទាំងការធ្វើទារុណកម្ម និងការវាយដំ។

### ឋ.៤. ទុក្ខវេទនា និងព្យសនកម្ម បណ្ដាលមកពីបទឧក្រិដ្ឋក្នុងករណី ០០២

ដើមបណ្ដឹងរដ្ឋប្បវេណី បានលើកឡើងថា អ្នកស្រី បានបាត់បង់មនុស្សជាទីស្រឡាញ់ជាច្រើនក្នុងអំឡុងសម័យខ្មែរក្រហម រួមទាំងស្វាមី កូនប្រុស ម្ដាយ និងបងប្រុសរបស់អ្នកស្រី។ លើសពីនេះទៅទៀត អ្នក

ស្រី បានប្រាប់តុលាការថា អ្នកស្រីបានទទួលបទពិសោធន៍ពីអំពើហិង្សា និងភាពសាហាវឃោរឃៅដោយផ្ទាល់ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។

### ឋ.៥. ឥរិយាបថរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងភាពគួរឱ្យជឿបាន

ដើមបណ្តឹងរដ្ឋប្បវេណី ហាក់ដូចជាមានការលំបាកខ្លាំង នៅពេលនឹកឡើងវិញពីព្រឹត្តិការណ៍ដ៏ឈឺចាប់ដែលអ្នកស្រីបានជួបប្រទះ។ អ្នកស្រី បានទ្រហោយំរហូតក្នុងផ្តល់សេក្តីថ្លែងការណ៍របស់អ្នកស្រី ចំពោះការរងទុក្ខវេទនា និងព្យសនកម្ម។ សក្ខីកម្មផ្ទាល់របស់អ្នកស្រី ក៏បានប៉ះពាល់ដល់សមាជិកផ្សេងៗទៀតក្នុងតុលាការ រួមមាន អ្នកបកប្រែអង់គ្លេស/ខ្មែរ និងព្រះរាជអាជ្ញា **រេន៉េ** ដែលបានជូតទឹកភ្នែកគាត់ អំឡុងពេលការធ្វើសេចក្តីថ្លែងការណ៍របស់សាក្សី។

## ផ្នែកទី ៣ ៖ បញ្ហាផ្លូវច្បាប់ និងនីតិវិធី

មានតែការជំទាស់មួយចំនួនប៉ុណ្ណោះ ត្រូវបានលើកឡើងនៅសប្តាហ៍នេះ ហើយភាគី ត្រូវបានសង្កេតឃើញថា មានការគោរព និងភាពអាណិតអាសូរនៅពេលសួរសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះ បានសង្កត់ធ្ងន់ទៅភាគីទាំងឡាយថា សេចក្តីថ្លែងការណ៍ពីការរងទុក្ខវេទនា មិនត្រូវបានរឹតត្បិតនៅក្នុងសំណុំរឿង ០០២/០១ នោះទេ។ ទោះជាយ៉ាងណា ភាគីទាំងឡាយ ទោរទន់ទៅរកការកំណត់សំណួរនៅក្នុងវិសាលភាពនៃសវនាការនៅដំណាក់កាលដំបូងនៃការជំនុំជម្រះ។ សិទ្ធិនៅស្ងៀមមិនឆ្លើយរបស់សហជនជាប់ ត្រូវបានការពារយ៉ាងពេញលេញនៅក្នុងសវនាការលើព្យសនកម្មនេះ។ បើទោះបីជាភាគីដើមបណ្តឹងរដ្ឋប្បវេណី បានអនុញ្ញាតឱ្យសួរសំណួរផ្ទាល់ទៅកាន់សហជនជាប់ចោទតាមរយៈប្រធានអង្គជំនុំជម្រះ អង្គជំនុំជម្រះ បានបញ្ជាក់ច្បាស់ថា សហជនជាប់ចោទ មានសេរីភាពបដិសេធមិនឆ្លើយសំណួរ។

### ក. នីតិវិធី និងវិសាលភាពនៃសេចក្តីថ្លែងការណ៍ពីការរងទុក្ខវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី

នីតិវិធីអនុវត្តសម្រាប់សវនាការលើព្យសនកម្មសប្តាហ៍នេះ បានគូសបញ្ជាក់ដោយសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៣។[17] ដោយអនុលោមតាមនីតិវិធី ដែលបានដាក់ចេញក្នុងសេចក្តីសម្រេចខាងលើចំពោះសេចក្តីថ្លែងការណ៍អំពីការរងការទុក្ខវេទនា មិនបានរឹតត្បិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នោះទេ។ តែនៅក្នុងការអនុវត្តពេញមួយសប្តាហ៍នេះ ភាគីទំនោរទៅរកការកំណត់សំណួររបស់ពួកគេ នៅក្នុងវិសាលភាពនៃសវនាការនៅដំណាក់កាលដំបូងនៃការជំនុំជម្រះ។ បន្ទាប់ពីការផ្ទៀងផ្ទាត់សួរអត្តសញ្ញាណរបស់ពួកគេដោយលោកប្រធានអង្គជំនុំជម្រះ ឬត្រូវបានសួរសំណួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីហើយ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ បានផ្តល់សេចក្តីថ្លែងការណ៍របស់ពួកគេទៅតុលាការ។

## ខ. សិទ្ធិនៅស្ងៀមមិនឆ្លើយរបស់សហជនជាប់ចោទ

កាលពីថ្ងៃចន្ទ មុនពេលចាប់ផ្ដើមនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះ បានសួរសហមេធាវីការពារក្ដីជនជាប់ចោទ **ខៀវ សំផន** និងលោក **នួន ជា** ថាតើសហជនជាប់ចោទ អាចនឹងជ្រើសរើសអនុវត្តសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបរបស់ខ្លួន នៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីសួរសំណួរដល់ពួកគេឬយ៉ាងណា? សហមេធាវីការពារក្ដីជនជាប់ចោទ បានប្រាប់តុលាការថា មិនមានកូនក្ដីណាមួយរបស់ពួកគេនឹងប្រើប្រាស់សិទ្ធិស្ងៀមមិនឆ្លើយតបនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេសម្រេចចិត្តថានឹងត្រូវឆ្លើយសំណួរ កាលណាពួកគេបានឮសំណួរ។ សហមេធាវីការពារក្ដីជនជាប់ចោទ **ខៀវ សំផន** បានស្នើថា កូនក្ដីរបស់លោកត្រូវត្រូវការសួរសំណួរទុកមុន។ សំណើនេះ ត្រូវបានបដិសេធ ហើយលោកប្រធានបានរម្លឹកសហមេធាវីការពារក្ដីថា សវនាការនេះ មានលក្ខណៈបែបតទល់គ្នា។ នៅពេញមួយសប្ដាហ៍ លោក **ខៀវ សំផន** បានជ្រើសរើសឆ្លើយតបទៅនឹងសំណួរទាំងអស់ដែលសួរទៅកាន់គាត់។ លោក **នួន ជា** បានឆ្លើយតបទៅនឹងសំណួរមួយចំនួន ប៉ុន្តែ បានបដិសេធមិនឆ្លើយតបក្នុងឱកាសជាច្រើនដោយផ្អែកលើមូលដ្ឋានថា លោកមិនមានសុខភាពល្អគ្រប់គ្រាន់ដើម្បីឆ្លើយសំណួរនោះទេ។

## គ. សំណួរច្រំដែល

ក្នុងអំឡុងពេលនៃការផ្ដល់សេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីលោក **យស ផល** សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី **បេនី យេ (Mrs. Beini Ye)** បានលើកឡើងពីបញ្ហានៃការប្រើប្រាស់សំណួរច្រំដែលក្នុងសួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី។ ក្នុងអំឡុងពេលសួរសំណួរ សហមេធាវីការពារក្ដីជនជាប់ចោទ **នួន ជា** គឺលោក **វិចទ័រ កូប៉េ (Mr. Victor Koppe)** បានសួរសំណួរដើមបណ្ដឹងរដ្ឋប្បវេណី ម្ដងហើយម្ដងទៀត អំពីសេចក្ដីថ្លែងការណ៍អំពីការបោសសម្អាតទាហាន **លន់ នល់**។ សំណួរជាច្រើនបានជំរុញឱ្យសហមេធាវីអន្តរជាតិដើមបណ្ដឹងរដ្ឋប្បវេណី អ្នកស្រី **បេនី យេ** ធ្វើអន្តរាគមន៍ស្នើសុំប្រធានឱ្យបញ្ឈប់សហមេធាវីអន្តរជាតិលោក **កូប៉េ** ពីការចោទសំណួរច្រំដែលលើប្រធានបទដូចគ្នា។ លោកប្រធាន បានសម្រេចបដិសេធការជំទាស់នេះ ប៉ុន្តែបានសួរសំណួរដដែលៗទៅដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធានាឲ្យបានថា ដើមបណ្ដឹងរដ្ឋប្បវេណី អាចយល់បាន។ សាក្សី បានឆ្លើយតបយ៉ាងខ្លីថា លោកបានឃើញព្រឹត្តិការណ៍នេះដោយផ្ទាល់ ហើយមិនមានអ្វីនិយាយបន្ថែមទៀតនៅលើបញ្ហានេះទេ។

# ផ្នែកទី ៤៖ ការគ្រប់គ្រងសវនាការ

សប្ដាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានដឹកនាំកិច្ចដំណើរការនីតិវិធីយ៉ាងមានប្រសិទ្ធភាពក្នុងការស្ដាប់សេចក្ដីថ្លែងការណ៍អំពីព្យសនកម្ម និងទុក្ខវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១២ រូប។

## ក. វត្តមាន

នៅពេញសប្ដាហ៍នេះ លោក **ខៀវ សំផន** បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការ ខណៈដែលលោក **នួន ជា** បានសង្កេតសវនាការ និងផ្ដល់ការឆ្លើយតបរបស់លោកទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីពីបន្ទប់ឃុំឃាំងដោយសារតែបញ្ហាសុខភាព។

**វត្តមានដើមបណ្តឹងរដ្ឋប្បវេណី:** នៅសប្តាហ៍នេះ មានសាក្សី ១០នាក់ បានមកសង្កេតកិច្ចដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការ ហើយដែលប្រហែលជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២០នាក់ បានសង្កេតពីសាលសាធារណជន។

**វត្តមានភាគី:** រាល់ភាគីទាំងអស់ ត្រូវបានតំណាងយ៉ាងត្រឹមត្រូវនៅក្នុងអំឡុងសប្តាហ៍នេះ។

| កាលបរិច្ឆេទ | ពេលព្រឹក | ពេលរសៀល |
|---|---|---|
| ថ្ងៃចន្ទ ២៧/០៥/១៣ | • អ្នកភូមិ ៣៥០ នាក់ មកពីខេត្តសៀមរាប<br>• អ្នកសង្កេតការណ៍បរទេស ១៥ នាក់ | • អ្នកភូមិ ៣០០ នាក់មកពីខេត្តតាកែវ<br>• អ្នកសង្កេតការណ៍បរទេស ៥នាក់ |
| ថ្ងៃពុធ ២៩/០៥/១៣ | • សិស្ស ៦០០ នាក់ មកពីស្រុកកោះសុទិន ខេត្តកំពង់ចាម<br>• អ្នកធ្វើការអង្គការមិនមែនរដ្ឋាភិបាល ៥០ នាក់ មកពីភ្នំពេញ<br>• អ្នកសង្កេតការណ៍បរទេស VI P ១០ នាក់<br>• អ្នកសង្កេតការណ៍បរទេស ១៣ នាក់ | • សិស្ស ៣០០ នាក់ មកពីវិទ្យាល័យទូកមាស ខេត្តកំពត<br>• អ្នកសង្កេតការណ៍បរទេស ១០ នាក់ |
| ថ្ងៃព្រហស្បតិ៍ ៣០/០៥/១៣ | • សិស្ស ៦០០ នាក់មកពីខេត្តកំពង់ចាម<br>• អ្នកសង្កេតការណ៍បរទេស ១៣ នាក់ | • សិស្ស ៣០០ នាក់មកពីខេត្តកំពង់ចាម<br>• អ្នកសង្កេតការណ៍បរទេស ៣ នាក់ |

### ខ. ការគ្រប់គ្រងពេលវេលា

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានដំណើរការនីតិវិធីពីថ្ងៃចន្ទ ដល់ថ្ងៃព្រហស្បតិ៍ ដោយលើកលែងថ្ងៃអង្គារជាថ្ងៃឈប់សម្រាកជាសាធារណៈ។ អង្គជំនុំជម្រះសាលាដំបូង បានរៀបចំបញ្ចប់សេចក្តីថ្លែងការណ៍អំពីព្យសនកម្ម និងទុក្ខវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំង ១២រូប ដូចដែលបានគ្រោងទុកមុននៅពេលវេលាពេញមួយសប្តាហ៍នេះ។ លោកប្រធានាអង្គជំនុំជម្រះ បានបន្តរម្លឹកដល់ភាគី ពីពេលវេលាដែលនៅសេសសល់អនុញ្ញាតឱ្យតុលាការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួននាក់ក្នុងមួយថ្ងៃតាមកាលកំណត់។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងអំឡុងពេលការផ្តល់សក្ខីកម្មរបស់ **យស ផល** លោក **កូប៉េ** បានតវ៉ាថារយៈពេលប្រាំពីរនាទីបែងចែកទៅឱ្យក្រុមមេធាវីការពារក្តីនីមួយៗដូចជាការរឹតត្បិតខ្លាំងណាស់។ ដោយយល់ព្រមតាមសំណើនេះ អង្គជំនុំជម្រះសាលាដំបូង ក៏បានអនុញ្ញាតឱ្យក្រុមមេធាវីការពារក្តីរយៈពេលប្រាំនាទីបន្ថែមទៀតនៃពេលវេលាសួរសំណួរទៅកាន់បណ្តឹងរដ្ឋប្បវេណី។

### គ. បញ្ហាបច្ចេកទេស និងការបកប្រែ

សប្តាហ៍នេះ បញ្ហាការបកប្រែ និងបច្ចេកទេស បានចោទជាបញ្ហាប្រឈម។ នៅថ្ងៃចន្ទ ឃើញមានការរអាក់រអួលផ្នែកសំឡេងត្រូវបានកត់សម្គាល់ជាច្រើនដង។ អ្វីដែលគួរឱ្យកត់សម្គាល់ខ្លាំងនោះ គឺអំឡុង

ពេលនៃការសួរលោក **យស ផល** គ្មានការបកប្រែជាភាសាអង់គ្លេសរយៈពេលប្រាំទៅដប់នាទី។ កាលពីថ្ងៃពុធ អំឡុងពេលការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រី **ឆេង អេងលី** ដែលផ្តល់តាមមធ្យោបាយសោតទស្សន៍ មានបញ្ហាបច្ចេកទេសអ៊ិនធើណិត បានជំរុញឱ្យអង្គជំនុំជម្រះពន្យារពេលនៃការផ្តល់សក្ខីកម្មរបស់អ្នកស្រី។ បន្ទាប់ពីការស្នើរសុំរបស់សហមេធាវីការពារក្តីលោក **នួន ជា** កាលពីថ្ងៃចន្ទ អង្គជំនុំជម្រះ បានរៀបចំនៅសម្ភារបរិក្ខារសំឡេង ចាប់ពីថ្ងៃព្រហស្បតិ៍ដើម្បីអាចអនុញ្ញាតឱ្យលោក **នួន ជា** ឆ្លើយសំណួររបស់សាក្សីពីបន្ទប់ឃុំឃាំង។ នៅពេញសប្តាហ៍នេះ អ្នកតាមដានសវនាការបានកត់សម្គាល់កំហុសនៃការបកប្រែមួយចំនួនដែលអាចត្រូវបណ្តាលមកពីផ្លាស់ប្តូរយោបល់គ្នាលឿនពេក និងគ្មានភាពច្បាស់លាស់មួយផ្នែកខ្លះនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែមានការខ្វះខាត។[18]

### ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ពេលព្រឹក សវនាការទី១ | ពេលព្រឹក សវនាការទី២ | ពេលរសៀល សវនាការទី១ | ពេលរសៀល សវនាការទី២ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|
| ថ្ងៃចន្ទ ២៧/០៥/១៣ | ៩:០៥-១០:២៩ | ១០:៤៩-១២:០២ | ១៣:២៦-១៥:០៤ | ១៥:២៣-១៦:២៤ | ៥ ម៉ោង ១៦ នាទី |
| ថ្ងៃពុធ ២៩/០៥/១៣ | ៩:០៩-១០:៥០ | ១១:០៧-១២:១១ | ១៣:៣៣-១៤:៥៣ | ១៥:១៤-១៦:០២ | ៤ ម៉ោង ៥៣ នាទី |
| ថ្ងៃព្រហស្បតិ៍ ៣០/០៥/១៣ | ៩:០១-១០:៤៥ | ១១:០២-១២:០០ | ១៣:២២-១៤:៣២ | ១៤:៥០-១៦:០៣ | ៥ ម៉ោង ៥ នាទី |
| | | | | | |
| ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយថ្ងៃ ៖ | | | ៥ ម៉ោង និង ០៥ នាទី | | |
| ចំនួនម៉ោងសរុបក្នុងសប្តាហ៍នេះ ៖ | | | ១៥ ម៉ោង និង ១៤ នាទី | | |
| ចំនួនសរុបនៃម៉ោងថ្ងៃនិងសប្តាហ៍ ៖ | | | ៧៩៥ ម៉ោង និង ៣២ នាទី | | |
| **សវនាការរយៈពេល ១៨៣ ថ្ងៃ ក្នុងអំឡុងពេល ៥៨ សប្តាហ៍** | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East sia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Chhaya Chhin, Phalla Chhoeun, Pheakdey Chum, Melanie Hyde, Anne Lang, Aviva Nababan, Sarun Sous, Kimsan Soy, Chhayrath Tan and Penelope Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] Trial Chamber. Transcript of Trial Proceedings (6 December 2012). E1/149.1 [hereinafter 6 DECEMBER TRANSCRIPT]. Lines 16-17.28.

[2] Olsen, Lars. "The Purpose of Hearing Victims' Suffering," Extraordinary Chamber in the Courts of Cambodia's Official Site. (7 June 2013) accessible at http://www.eccc.gov.kh/en/blog/2013/06/07/purpose-hearing-victims-suffering

[3] Trial Chamber. Decision on Request To Recall Civil Party TCCP-187, for Review of Procedure Concerning Civil Parties' Statements on Suffering and Related Motions and Responses (E240, E240/1, E250, E250/1, E267, E267/1 AND E267/2) (02 May 2013)". E267/3.

[4] Trial Chamber. Decision on Request To Recall Civil Party TCCP-187, for Review of Procedure Concerning Civil Parties' Statements on Suffering and Related Motions and Responses (E240, E240/1, E250, E250/1, E267, E267/1 AND E267/2) (02 May 2013)". E267/3.

[5] Sou Sotheavy was examined in the following order: President Nil Nonn; National Civil Party Lawyer Sin Soworn; International Co-Prosecutor Vincent de Wilde d'Estmael; International Co-Lawyer for Khieu Samphan, Arthur Vercken.

[6] Aun Phally was examined in the following order: President Nil Nonn; National Civil Party Co-Lawyer Veng Pov; National Senior Assistant Prosecutor Chan Dararasmey; National Defense Lawyer for Nuon Chea Son Arun; National Defense Lawyer for Khieu Samphan Kong Sam Onn.

[7] Sang Rath was examined in the following order: President Nil Nonn; National Civil Party Lawyer Ven Pov; National Senior Assistant Prosecutor Dararasmey Chan.

[8] Yos Phal was examined in the following order: President Nil Nonn; Civil Party Lawyer, Sin Soworn; International Co-Prosecutor, Vincent de Wilde d'Estmael; International Co-Lawyer for Nuon Chea, Victor Koppe, and International Co-Lawyer for Khieu Samphan, Arthur Vercken.

[9] Thouch Phandara was examined in the following order: President Nil Nonn; International Civil Party Lawyer Marie Guiraud; International Prosecutor Keith Raynor; National Co-Lawyer for Nuon Chea Son Arun; International Co-Lawyer for Nuon Chea Victor Koppe

[10] Chan Socheat was examined in the following order: President Nil Nonn; International Civil Party Lawyer Christine Martinneau; Marie Guiraud; International Prosecutor Keith Raynor; and National Co-Lawyer for Khieu Samphan Kong Sam Onn.

[11] Huo Chhanta was not examined by any party, only President Nil Nonn, although her counsel National Civil Party Lawyer Ty Sirnia preceeded the Civil Party's statement of suffering and testimony with an introduction.

[12] Cheng Eng Ly was examined in the following order: President Nil Nonn; International Civil Party Lawyer Pascal Auboin and National Prosecutor Seng Bunkheang.

[13] Civil Party Nou Hoan was examined in the following order: President Nil Nonn; National Civil Party Lawyer Sam Sokong; National Co-Prosecutor Seng Bunkheang; National Co-Lawyer for Nuon Chea, Son Arun; National Co-Lawyer for Khieu Samphan, Kong Sam Onn; and International Co-Lawyer for Khieu Samphan, Arthur Vercken.

[14] The Civil Party was exanimated only by the President, the Civil Party´s Council Chet Vanly, and International Prosecutor Dale Lysak and by National Prosecutor Kong Sam Onn.

[15] It was unclear during the testimony whether it was his grandmother or aunt (or both of them) staying in the village.

[16] The Civil Party was examined in the following order: President Nil Nonn; Civil Party Lawyer, Ty Srina, International Prosecutor Dale Lysak, and National Co-Lawyer for Nuon Chea, Son Arun.

[17] The allowance for the statement of suffering to go beyond the scope of case 002/01 has been determined in a temporary verbal ruling by Judge Lavergne in October 2012. See CASE 002 KRT TRIAL MONITOR. Issue 41. Hearing on Evidence Week 36 (22-25 October 2012).p. 11-12. This position was further confirmed by the Trial Chamber's decision on this matter. See Trial Chamber. Decision on Request To Recall Civil Party TCCP-187, for Review of Procedure Concerning Civil Parties' Statements on Suffering and Related Motions and Responses (E240, E240/1, E250, E250/1, E267, E267/1 AND E267/2) (02 May 2013)". E267/3. Specifically in paragraph 14 of the decision, the Trial Chamber noted that it has always differentiated between testimony of facts, which had to be confined to the scope of Case 002/01, and the Civil Parties' general statements of suffering. In page 10 of the decision it is also stipulated that the Lead Co-Lawyers of the Civil Parties have to structure their examination of their clients "in a manner that differentiates between testimony on facts and statements pertaining to suffering."

[18] For example, during Chan Socheat's testimony, the English translation stated that she met Nuon Chea on a bicycle. However, the Khmer translation stated that it was Ta Mok whom she met.